# សង្ខេបប្រតិបត្តិ

Draft

*រៀបរៀងដោយ **ឃី ខនសាល់ធេន (ខេមបូឌា)** KCC*

# សង្ខេបប្រតិបត្តិ

## ១. សេចក្តីផ្តើម

គំរោង**មរកត**គឺបានទទួលសិទ្ធិពេញលេញក្នុងការវិនិយោគរបស់ក្រុមហ៊ុនឯកជន "**កោះពស់ (ខេមបូឌា) អ៊ិនវេសមេនគ្រុប អិលធីឌី**"។ យោងទៅតាមកិច្ចព្រមព្រៀងដើមរវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុន **កោះពស់ (ខេមបូឌា) អ៊ិនវេសមេនគ្រុប អិលធីឌី** បានធ្វើកិច្ចសន្យាជួលដីកោះពស់ និងឆ្នេរហាវ៉ៃ រយៈពេល ៩៩ឆ្នាំ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៦។

នៅក្នុងប្លង់មេនៃគំរោងនេះ រួមមាន៣ផ្នែកសំខាន់ៗ គឺ ការអភិវឌ្ឍលើកោះពស់ ការអភិវឌ្ឍលើឆ្នេរហាវ៉ៃ និងការសាងសង់ស្ពានកោះពស់។ តំបន់កោះពស់ គឺមានសក្តានុពលខ្ពស់ក្នុងការអភិវឌ្ឍវិស័យទេសចរណ៍ ដោយសារតែភាពសំបូរបែបនៃធនធានធម្មជាតិរួមទាំងឆ្នេរខ្សាច់ដ៏ធំស្អាត និងមានខ្សាច់ពណ៌ស ទឹកថ្លាស្អាត និងមានព្រៃឈើយ៉ាងល្អផងដែរ។

ការសិក្សាគឺដើម្បីបំពេញអនុសាសន៍របស់ក្រសួងបរិស្ថាន និងក្រសួងពាក់ព័ន្ធក្នុងការឯកភាពជាគោលការណ៍លើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូងក្នុងឆ្នាំ២០០៨ ដោយសារតែគំរោងមរកតត្រូវបានចាត់ថ្នាក់ជាហេដ្ឋារចនាសម្ព័ន្ធធំៗ ហើយបានតំរូវឱ្យសិក្សាការវាយតំលៃហេតុប៉ះពាល់បរិស្ថាន។ គោលបំណងនៃរបាយការណ៍នេះគឺ ដើម្បីបង្ហាញលទ្ធផលនៃការសិក្សាការវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញសំរាប់គំរោងអភិវឌ្ឍន៍ទាំងហេតុប៉ះពាល់វិជ្ជមាន និងអវិជ្ជមាន ហេតុប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោល ទៅលើធនធានធម្មជាតិ និងសង្គម នៅក្នុង និងជុំវិញតំបន់គំរោង។

ទំហំនៃការសិក្សាការវាយតំលៃហេតុប៉ះពាល់បរិស្ថាន គ្របដណ្តប់ទាំងគុណប្រយោជន៍បរិស្ថាន និងសង្គម និងផលប៉ះពាល់កើតចេញពីរាល់ទិដ្ឋភាពទាំងអស់របស់គំរោង នៅក្នុងការកំណត់ចំណាត់ថ្នាក់យ៉ាងទូលាយនៃធនធានបរិស្ថាន និងគុណតំលៃនៅក្នុងតំបន់គំរោង: បរិស្ថានរូបសាស្ត្រ រួមមាន ដី ទឹក និងបរិយាកាស, បរិស្ថានជីវសាស្ត្រ រួមមាន សត្វ និងរុក្ខជាតិ នៅលើគោក និងនៅក្នុងទឹក ព្រមជាមួយនឹងជំរករបស់ពួកវា, បរិស្ថានសង្គម រួមមាន ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត សេវាកម្មសុខមាលភាព និងគ្រឿងបរិក្ខាបំរើឱ្យសុខមាលភាព ការងារ ការអប់រំ និងការអភិវឌ្ឍសេដ្ឋកិច្ចទូទៅ ព្រមទាំងតំបន់វប្បធម៌ វត្ថុបុរាណ និងគុណភាពនៃការរស់នៅក្នុងតំបន់គំរោង។

វិធីសាស្ត្រជាទូទៅ ដែលបានយកមកប្រើប្រាស់ នឹងសង្ខេបជូនដូចខាងក្រោម:

- ការប្រមូល និងពិនិត្យមើលទិន្នន័យ
- កិច្ចប្រជុំ និងការពិគ្រោះយោបល់
- ការអង្កេតលើធនធានធម្មជាតិ

Draft

- ការអង្កេតធនធានសង្គម
- ការវិភាគ និងវាយតម្លៃសក្តានុពលនៃហេតុប៉ះពាល់បរិស្ថាន
- ការវិភាគសេដ្ឋកិច្ច
- ការរៀបចំចងក្រងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ។

## ២. ការពណ៌នាពីគំរោង

គំរោង**មរកត** គឺជាគំរោងរបស់ក្រុមហ៊ុន **កោះពស់ (ខេមបូឌា) អ៊ិនវេសមេនគ្រុប អិលធីឌី** ដែលជាក្រុមហ៊ុនវិនិយោគដើមមកពីប្រទេសរ៉ុស្ស៊ី។ នៅក្នុងប្រទេសកម្ពុជាក្រុមហ៊ុន មានការិយាល័យនៅ ផ្ទះលេខ ០៦៣ ផ្លូវឯករាជ្យ ស្ថិតនៅក្នុងក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ប្រទេសកម្ពុជា។ អ្នកទទួលខុសត្រូវរបស់ក្រុមហ៊ុនគឺ លោក ANDREW HALTURIN ដែលមានតួនាទីជានាយកគំរោង។

គំរោង**មរកត** គឺស្ថិតនៅក្នុងភូមិ១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុនៃព្រះរាជាណាចក្រកម្ពុជា សូមមើល ទីតាំងភូមិសាស្ត្រនៅក្នុងរូបភាព ៣.២-១។ តំបន់គំរោងគឺមានចំងាយប្រហែល២៣០គីឡូម៉ែត្រពីរាជធានីភ្នំពេញ និងអាចធ្វើដំណើរទៅដល់ដោយផ្លូវជាតិលេខ៤ ឬក៏តាមរយៈផ្លូវដែកភាគខាងត្បូង (ភ្នំពេញ-ក្រុងព្រះសីហនុ)។ គំរោង មរកតនេះមានសមាសភាព៣សំខាន់ៗគឺ:

- **ស្ពានកោះពស់:** គឺជាស្ពានបេតុង ដោយមានប្រវែងសរុប៩០០ម៉ែត្រ ទទឹង១២ម៉ែត្រ និងមានកំពស់ ៣២,៩ម៉ែត្រ។ មានផ្លូវកៅស៊ូប្រភេទបីទូមមីនីប្រវែងរាប់រយម៉ែត្រទាំងសងខាងស្ពានរួមទាំងការសាងសង់ស្ពាន ។ *តំលៃសរុបនៃការសាងសង់ស្ពានកោះពស់ គឺមានប្រហែល* ***៥០លានដុល្លាអាមេរិក***។
- **ការអភិវឌ្ឍលើឆ្នេរបាវៃ** គំរោងនេះមានសមាសភាពចំនួន១០ផ្នែក មានដូចជា សណ្ឋាគារលំដាប់ផ្កាយ និងលំនៅដ្ឋានខ្ពស់ៗ ផ្សារពាណិជ្ជកម្មដែលមានចំណតរថយន្តពីរជាន់ខាងក្រោមដី ផ្សារពាណិជ្ជកម្មជាមួយចំណតនិងយានដ្ឋាន អគារការិយាល័យកំពស់មធ្យម បន្ទប់តាំងពិពណ៌តូចៗនៅជុំវិញតំបន់ប៉ៃតង, ភូមិគ្រឹះដោយមានបំពាក់អាងហែលទឹកឯកជន, ក្លឹបកំសាន្ត, ភោជនីយដ្ឋានអាហារសមុទ្រ ទីតាំងមើលថ្ងៃរៀបលិច និងបន្ទប់ស្ប៉ា។ *តំលៃនៃការអភិវឌ្ឍលើឆ្នេរបាវៃគឺ* ***៩០លានដុល្លាអាមេរិក***។
- **ការអភិវឌ្ឍលើកោះពស់:** គំរោងនេះបានបែងចែកជា១៤ផ្នែក ដូចជា តំបន់ឆ្នេរខ្សាច់ តំបន់សកម្មភាពឈូងសមុទ្រ តំបន់សាធារណៈ តំបន់ទីតាំងអាគារខ្ពស់ៗ ទីតាំងទេសភាពដោយមានវត្តអារ៉ាម កាស៊ីណូ តំបន់លក់ទំនិញ តំបន់លំនៅដ្ឋាន រមណីយដ្ឋាន និងឧទ្យាន ទីលានកីឡា តំបន់អភិរក្សសត្វព្រៃដោយមានច្រកដើរកំសាន្ត តំបន់តាំងទីលំនៅដ្ឋានក្នុងព្រៃធម្មជាតិ និងតំបន់អភិរក្សសត្វព្រៃ។ នៅក្នុងតំបន់ទាំងនោះមានសេវាកម្មសាធារណៈជាច្រើនទៀត និងសេវាកម្មទេសចរណ៍ ត្រូវបានគេរៀបចំផែនការនៅក្នុងតំបន់នីមួយៗ ក្នុងនោះមានដូចជា សាលារៀន គ្លីនិក វត្តអារ៉ាម ស្ថានីយ៍ប៉ូលីស



Draft

សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលពាណិជ្ជកម្ម/ហាង ។ល។ *តំលៃប៉ាន់ស្មាននៃការអភិវឌ្ឍ នៅលើកោះពស់ គឺមានប្រហែល ៣០០លានដុល្លាអាមេរិក។*

ការងារសំណង់នៃគំរោងទាំងមូល នឹងត្រូវបានធ្វើឡើងដោយអ្នកម៉ៅការជាតិ និងអន្តរជាតិ។ តំរូវការកំលាំងពលកម្មសរុប(រាប់ទាំងអ្នកមានជំនាញ និងអត់ជំនាញ) គឺ៩៩៥នាក់ នៅក្នុងដំណាក់ការសាងសង់ និង ១៤៧៦នាក់ នៅក្នុងដំណាក់ការប្រតិបត្តិការ។

គំរោងការអនុវត្តជាទូទៅរបស់គំរោងត្រូវបានរៀបចំផែនការពេលវេលាមានដូចខាងក្រោម:

- ការសាងសង់ស្ពានកោះពស់: ២០០៨-២០១០ (រយៈពេល៣ឆ្នាំ)
- ការអភិវឌ្ឍលើឆ្នេរបាវី: ២០០៩-២០១២ (រយៈពេល៤ឆ្នាំ)
- ការអភិវឌ្ឍលើកោះពស់: ២០១០-២០១៥ (រយៈពេល៦ឆ្នាំ)

គំរោងនេះគឺជាប្រភេទគំរោងវិនិយោគឯកជនដែលមានរយៈពេល៩៩ឆ្នាំ រួមទាំងរយៈពេលសាងសង់ និង ប្រតិបត្តិការ នេះបើយោងតាមកិច្ចសន្យាជួលដី រវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុន **កោះពស់ (ខេមបូឌា) អ៊ិនវេសមេនគ្រុប** ដូច្នេះលក្ខខ័ណ្ឌគំរោងដូចគ្នាទៅនឹង **គំរោងប្រតិបត្តិការ សាងសង់ និងផ្ទេរ (BOT)** ដែលមានតំលៃវិនិយោគសរុបទាំងអស់គឺ **៤៤០ លានដុល្លាអាមេរិក**។

## ៣. ការពណ៌នាពីបរិស្ថាន

### ៣.១. ធនធានរូបសាស្ត្រ

- **បរិយាកាស**

តំបន់គំរោង គឺមានអាកាសធាតុត្រូពិចម៉ូសុង ដែលមានរដូវសំខាន់ៗពីរគឺ រដូវប្រាំង និងរដូវវស្សា។ រដូវវស្សាចាប់ផ្តើមពីខែឧសភា និងបញ្ចប់នៅក្នុងខែតុលា ហើយរដូវប្រាំងគ្របដណ្តប់នៅក្នុងខែវិច្ឆិកា ដល់ខែមេសា។ កំពស់ទឹកភ្លៀងមធ្យមប្រចាំឆ្នាំនៅក្នុងអំឡុងពេល៨ឆ្នាំចុងក្រោយនេះ(២០០០-២០០៧) គឺ ៣.២១៨មម។

សីតុណ្ហភាពអតិបរមាមធ្យមប្រចាំខែនៅក្នុងតំបន់គំរោងគឺមានចន្លោះពី៣០-៣៣ អង្សាសេ និងអប្បបរមាមធ្យមប្រចាំខែគឺមានចន្លោះពី ២២.៨-២៥.២ អង្សាសេ។ សីតុណ្ហភាពក្តៅបំផុតគឺ ៣៤.៥ អង្សាសេ ហើយកើតមាននៅក្នុងខែមេសា និងខែឧសភា និងសីតុណ្ហភាពអប្បបរមាទាបបំផុតគឺ ២០.៤ អង្សាសេ និងកើតមាននៅក្នុងខែធ្នូ និងខែកុម្ភៈ។

ជាលទ្ធផលនាំឱ្យតំបន់គំរោងមានសំណើមខ្ពស់ ដែលកំរិតសំណើមអប្បបរមានៅក្នុងស្ថានីយ៍ខេត្តព្រះសីហនុមានចន្លោះពី៧០-៨៨% និងមានសំណើមមធ្យមចន្លោះពី៨២-៩៤%។

ដោយយោងទៅតាមទិន្នន័យពីទិស និងល្បឿនខ្យល់ប្រចាំខែ នៅក្នុងស្ថានីយ៍ព្រះសីហនុ ក្នុងរយៈពេល៨ឆ្នាំចុងក្រោយ ២០០០-២០០៨ បានបង្ហាញថា: ពីខែកុម្ភៈ ទៅដល់ខែមេសា ទិសខ្យល់ភាគច្រើនបានបក់ពីទិសខាងត្បូង



Draft

អាគ្នេយ៍ និរតី ដោយមានល្បឿន ពី៤-៧ម/វិនាទី។ ពីខែឧសភាដល់ខែតុលាខ្យល់បានបក់ពីលិច-និរតី លិច-ពាយ័ព្យដោយមានល្បឿនពី៨-១២ម/វិនាទីនិង។ ពីខែវិច្ឆិកា ដល់ខែមករា ខ្យល់បក់ពីទិសខាងជើង ជើង-ឦសាន និងឦសាន ដោយមានល្បឿន៦-៧ម/វិនាទី។

- **ប៉ានលេខា និងដី**

ទីតាំងប្លង់គំរោងនៅក្នុងតំបន់កោះពស់ដែលគ្របដណ្តប់លើ កោះពស់ ឆ្នេរហាវ៉ៃ និងដែនដីក្រុងព្រះសីហនុនោះមានកំរិតកំពស់អតិបរិមា៦០ម៉ែត្រ និងកំរិតកំពស់អប្បបរមា -១៧ម៉ែត្រ (បាតឃ្លងធម្មជាតិនៃតំបន់កោះពស់)។ ទោះជាយ៉ាងណាក៏ដោយ កំរិតកំពស់អតិបរមានៅលើកោះពស់គឺ ៤៤ម៉ែត្រតែប៉ុណ្ណោះ។ ដីស្រទាប់ លើរបស់កោះ និងតំបន់ដីគោកគឺមានលក្ខណៈស្តើងណាស់ (មានកំរាស់ពី០.២-១ម) ដែលជាដីល្បាយខ្សាច់ និងខ្សាច់ម៉ត់។ ដុំថ្ម ឬសំណឹកថ្ម និងផ្ទាំងថ្មធំៗឃើញមាននៅបន្ទាប់ពីស្រទាប់ដីខាងលើ។

- **ភូគព្ភសាស្ត្រ**

ពីការអង្កេតតាមដាននៅក្នុងទីតាំងជាក់ស្តែងបានបង្ហាញថា ថ្មភក់គឺមាននៅក្នុងគំនូរព្រៀងជាទូទៅនៅក្នុងតំបន់កោះពស់។ លក្ខខ័ណ្ឌភូគព្ភសាស្ត្រនៃរណ្តៅខួងក្នុងទីតាំងគំរោងបានបង្ហាញយ៉ាងច្បាស់នៃការបែងចែកទៅតាមទីតាំងភូគព្ភសាស្ត្រដូចខាងក្រោម:

១) ០ ដល់ ១៧.៣៦ម៉ែត្រ គឺថ្មភក់ដែលបានរងនូវសំណឹកខ្លាំង

២) ១៧.៣៦ ដល់ ២៤.៧៦ម៉ែត្រ គឺថ្មភក់ដែលបានរងនូវសំណឹកមធ្យម

- **ជលវិទ្យា**

<u>**ទឹកលើដី:**</u> ជាទូទៅចរន្តទឹកនៅក្នុងតំបន់គំរោងហាក់ដូចជាមានសភាពហ្មឹង និងស្ងប់ស្ងាត់នៅក្នុងអំឡុងពេលរដូវប្រាំង។ ប៉ុន្តែ នៅក្នុងអំឡុងពេលរដូវវស្សា ចរន្តទឹកអាចត្រូវបានប្រែប្រួលដោយសារស្ថានភាពខ្យល់ និងរលក។ ចរន្តទឹកហូរហាក់បីដូចជាវិលជុំវិញកោះតាមឃ្លងពីទិសនិរតីទៅទិសឦសាន នៅក្នុងខែមីនា ឆ្នាំ២០០៨។ ប៉ុន្តែវាបានផ្លាស់ប្តូរទិសពីឦសាន ទៅទិសនិរតីវិញ នៅក្នុងខែមេសា-ឧសភា ឆ្នាំ២០០៨។

ក្នុងរដូវវស្សា រលកជាញឹកញាប់មានកំពស់ពី ០.៥ម ទៅ ០.៩ម និងជួនកាល មានកំពស់ ពី១.៥ម ទៅ ២ម ពេលមានខ្យល់ខ្លាំង។ នៅក្នុងរដូវប្រាំងស្ថានភាពរលកជាធម្មតាមានសភាពស្ងប់ស្ងាត់ ប៉ុន្តែ អាចមានម្តងម្កាលរលកពី០.៤ម ទៅ ០.៧ម។ ជាទូទៅមានទឹកជោរនាច២ដងក្នុងមួយថ្ងៃ ក្នុងនោះម្តងជំនោរ និងម្តងទៀតលំនាច។ ទឹកនោរជាមធ្យមគឺមានកំពស់ពី ០.៥-១ម។ កំពស់ទឹកជំនោរអាចឡើងទៅដល់ ១-១.៥ម ក្នុងខែវិច្ឆិកាដល់ខែមករា។ ទឹកនាចមានកំពស់ទាបជាងកំពស់ទឹកធម្មតាពី០.៥-០.៨ម។

Draft

**ទឹកក្រោមដី:** ក្រុងព្រះសីហនុគឺសំបូរទៅដោយទឹកក្រោមដី ជាពិសេសនៅក្នុងខ័ណ្ឌមិត្តភាព ទោះបីជាយ៉ាងណាក៏ដោយ បណ្តាញទឹកក្រុងត្រូវបានប្រើប្រាស់ជាប្រភពទឹកទីពីរផងដែរ។ មានសណ្ឋាគារ និងផ្ទះសំណាក់ជាច្រើនបានប្រើទឹកក្រោមដីសំរាប់តំរូវការទឹកផ្ទាល់ខ្លួនរបស់ពួកគេ។ ជំរកទឹកក្រោមដីគឺស្ថិតនៅជំរៅជ្រៅជាង២៥ម៉ែត្រ។

## ៣.២. ធនធានជីវសាស្ត្រ

- **ជលផល/ត្រី**

តំបន់នេសាទនៅកោះពស់គឺមានទំហំតូចជាមួយនឹងផលិតកម្មតិចតួច និងសកម្មភាពនេសាទមានរយៈពេលខ្លីប្រហែល២ខែនៅរដូវប្រាំង ធៀបទៅនឹងតំបន់នេសាទដ៏ទៃទៀតនៅក្នុងខេត្តព្រះសីហនុ។ ក្នុងរយៈពេលនេសាទត្រី ២ខែនៅជុំវិញកោះពស់ ដោយអ្នកនេសាទដែលបានជ្រើសរើសចំនួន ១១នាក់ អាចធ្វើការសន្និដ្ឋានលទ្ធផលដូចខាងក្រោម:

- មានត្រីសមុទ្រចំនួន ៣៩ប្រភេទ ត្រូវបានគេចាប់នៅក្នុងអំឡុងពេលសិក្សា។
- មានត្រីសមុទ្រចំនួន ៦៥ប្រភេទ បានរាយការដោយអ្នកផ្តល់បទសំភាសន៍ និង ធ្វើPRA ។
- មានត្រីសមុទ្រចំនួន ១៧ប្រភេទជាប្រភេទសំខាន់សំរាប់ទ្រទ្រង់ជីវភាពប្រជាជនមូលដ្ឋាន។
- គ្មានប្រភេទត្រីងាយរងគ្រោះថ្នាក់ណាមួយដែលបានរកឃើញនៅក្នុងតំបន់គំរោងក្នុងអំឡុងពេលសិក្សានោះទេ។
- ប្រាក់ចំណូលមធ្យមប្រចាំថ្ងៃគឺមានចំនួន ១៥០.០០០រៀល/គ្រួសារដែលមានទូកនេសាទ១ ជាធម្មតាគឺមានមនុស្ស២នាក់ក្នុងប្រភេទទូកនេសាទបែបគ្រួសារ១គ្រឿង។
- ការប៉ាន់ប្រមាណផលចាប់សំរាប់តំបន់នេសាទកោះពស់ គឺមានចំនួន ៦៧.១៥តោន/ឆ្នាំ។
- តំលៃប៉ាន់ប្រមាណសរុបគឺ មានចំនួន ១០៧.២១២ ដុល្លាអាមេរិក/ឆ្នាំ។
- ចំណូលបន្ថែមនៃគ្រួសារនេសាទនៅក្នុងភូមិ១ និងភូមិ៣ គឺបានចំណូលពីការជួលទូកឱ្យអ្នកទេសចរណ៍ដើម្បីនេសាទកំសាន្តលំហែកាយ។

- **ការអង្កេតលើផ្កាថ្ម**

គ្រប់ទីតាំងអង្កេតទាំងអស់ជុំវិញកោះពស់ក្នុងចំណោមត្រីចំនួន៩ប្រភេទនៃគំរូកំណត់សំរាប់ធ្វើការអង្កេតមានតែត្រីចំនួន៤ប្រភេទប៉ុណ្ណោះដែលគេប្រទះឃើញ និងកត់ត្រាក្នុងនោះមានត្រីមេអំបៅ ត្រី sweetlips ត្រី parrotfish

Draft

និងត្រីតុកែ ។ ចំពោះប្រភេទត្រីផ្សេងទៀតដែលមិនមានវត្តមាននៅតាមទីតាំងអង្កេតទាំង១១កន្លែងនោះទេ គឺហាក់ដូចជាទទួលរងនូវការនេសាទហួសកំរិត ឬក៏លក្ខខណ្ឌរបស់ផ្កាថ្មមិនល្អសំរាប់ការរស់នៅនៃប្រភេទត្រីទាំងនេះ ។

ចំពោះនិបិដ្ឋជីតសត្វវិញ ឃើញមានជារឿយៗ នូវប្រភេទ Diadema urchin ***(Diadema setosum)*** នៅគ្រប់ទីតាំងអង្កេតទាំងអស់ ចំណែកប្រភេទ Collector urchins ***(Tripneustes spp)*** ប្រភេទ Triton ***(Charonia tritonis)*** និងប្រភេទ Giant clam ***(Tridacna sp)*** មួយចំនួនក៏ត្រូវបានប្រទះឃើញ និងបានកត់ត្រានៅក្នុងខ្សែបន្ទាត់នៃទីតាំងអង្កេតទាំងនោះផលដែរ ។

ការបំផ្លាញផ្កាថ្មដោយសារទូកនេសាទ ឬការបោះយុថ្កា សំណល់មង និងកាកសំណល់ផ្សេងៗទៀត ត្រូវបានអង្កេតឃើញមាននៅក្នុងអំឡុងពេលនៃការសិក្សា ប៉ុន្តែកំរិតខូចខាតទៅលើផ្កាថ្ម គឺមានកំរិតតិចតួច ។ មានតែ១០% នៃពពួកផ្កាថ្ម និង៦.២៥%នៃតំបន់ផ្កាថ្មត្រូវបានទទួលរងផលប៉ះពាល់ដោយសារជំងឺផ្សិតស (Bleaching) ។

ផ្អែកទៅលើលទ្ធផលនៃការធ្វើអង្កេតផ្កាថ្មទាំងនេះ បានឱ្យដឹងថា ជាទូទៅផ្កាថ្មស្ថិតនៅក្នុងលក្ខខ័ណ្ឌមួយល្អ ។ ទោះជាផ្កាថ្មស្ថិតនៅក្នុងលក្ខខ័ណ្ឌមួយល្អក៏ដោយ ក៏មានតែប្រភេទត្រី និងប្រភេទសត្វនិបិដ្ឋជីតមួយចំនួនប៉ុណ្ណោះដែលត្រូវបានគេកត់ត្រា និងប្រទេះឃើញនៅតាមខ្សែបន្ទាត់នៃទីតាំងអង្កេតទាំងអស់ ។ ប្រការនេះទំនងអាចបណ្តាលមកពីមានការរំខាន និងការប្រមូលផល/ការនេសាទហួសកំរិត ហើយភាគរយនៃពពួកផ្កាថ្មមានជីវិត គឺមានតិចជាងភាគរយនៃពពួកផ្កាថ្មគ្មានជីវិត ។

- **ព្រៃឈើ និងសត្វព្រៃ**

ការស្រាវជ្រាវព្រៃឈើ និងសត្វព្រៃ គឺផ្តោតសំខាន់ទៅលើការប៉ាន់ប្រមាណព័ត៌មានមួយចំនួនដែលមាន ស្រាប់នៅក្នុងតំបន់គំរោង ។ ការប៉ាន់ប្រមាណនេះគឺរួមមាន ប្រភេទដើមឈើ និងសត្វព្រៃ មាឌឈើឈរ តំលៃឈើ ចំនួនជីវម៉ាសសរុប ការស្តុកកាបូន សមត្ថភាពស្រូបកាបូនឌីអុកស៊ីតប្រចាំឆ្នាំ និងប្រភេទដែលងាយរងការគំរាមកំហែងផ្សេងៗ ។

**<u>ការធ្វើសារពើភ័ណ្ឌព្រៃឈើ</u>**

ទីតាំងគំរោងស្មើសុំមានផ្ទៃដីសរុប ១១៦.៦ហ.ត ក្នុងនោះរួមមាន៩៧ហ.ត ជាព្រៃស្រោង ។

តាមលទ្ធផលនៃការស្រាវជ្រាវ ព្រៃឈើនៅក្នុងតំបន់គំរោងប្រមាណ៩៧ហ.តនេះ យ៉ាងហោចណាស់ក៏មានរុក្ខជាតិប្រមាណ ១០៣ ប្រភេទ ដែលមានដង់ស៊ីតេឈើ ៤៩១ដើមក្នុង១ហិកតា ។ ចំពោះដង់ស៊ីតេនេះ មាន៨៤.៥% គឺជា ប្រភេទរុក្ខជាតិដែលគ្មានលំដាប់ថ្នាក់ឈើពាណិជ្ជកម្ម ហើយក្រៅពីនេះ មាន១%ជាឈើប្រណិត ១.៥%ជាឈើប្រភេទលេខ១ ៥.២%ជាឈើប្រភេទលេខ២ និង ៧.៧% ជាឈើប្រភេទលេខ៣ ។ គេបានរកឃើញប្រភេទឈើមួយចំនួនដែលជាចំណាត់ថ្នាក់នៃប្រភេទរងការគំរាមកំហែងនៅក្នុងបញ្ជីក្រហមនៃ IUCN ឆ្នាំ២០០០ ដូចជា "ឈើពពេល" "គគីរខ្សាច់" និង "ឈើទាលនាងដែង" ជាប្រភេទកំពុងរងគ្រោះ "ស្តៅភ្នំ" ជាប្រភេទជិតទទួលរង

គ្រោះថ្នាក់ ចំណែកឯ "គគីរភ្នង" ស្ថិតក្នុងចំណាត់ថ្នាក់ជិតផុតពូជ និងប្រភេទ "ក្រាយស ឬកាទ្បាវ" ស្ថិតក្នុងចំណាត់ថ្នាក់ងាយរងគ្រោះ ។

មាឌឈើឈរសរុបដែលមានអង្កត់ផ្ចិតអប្បរមា ១០ស.ម មាន ៨.៦០៣,៧០ម$^{៣}$ ដែលក្នុងនោះមានឈើប្រណិត៥៨,៧៧ម$^{៣}$ ឈើប្រភេទលេខ១មាន ១៦០.១៥ម$^{៣}$ ឈើប្រភេទលេខ២មាន ១.១១១,៨៣ម$^{៣}$ ឈើប្រភេទលេខ៣មាន ១.៤០០,១៥ម$^{៣}$ និងឈើគ្មានចំណាត់ថ្នាក់មាន ៥.៨៧២,១៣ម$^{៣}$ ។ យោងទៅតាម តារាងតំលៃឈើឈរនៅរដ្ឋបាលព្រៃឈើ ឆ្នាំ២០០៩ សំរាប់ឈើប្រណិត និងឈើលេខ១ គឺមានតំលៃ ៨១ដុល្លា/ម៉ែត្រគូប ប្រភេទឈើលេខ២មានតំលៃ ៥៤ដុល្លា/ម៉ែត្រគូប ហើយឈើលេខ៣ និងប្រភេទឈើគ្មានលំដាប់ថ្នាក់មានតំលៃ ៤៣ដុល្លា/ម៉ែត្រគូប ។

ជីវម៉ាសសរុប (រួមទាំងជីវម៉ាសផ្នែកខាងលើ និងខាងក្រោមផ្ទៃដី) គឺមានចំនួន ១៣.៨៧១ តោន។ កំនើនជីវម៉ាសប្រចាំឆ្នាំគឺ ១៣៥ តោន/ឆ្នាំ។ សមត្ថភាពស្រូបកាបូនឌីអុកស៊ីតនៃព្រៃឈើគឺ ៥២៤ តោន/ហ.ត ក្នុងមួយឆ្នាំ ដោយធ្វើការប៉ាន់ស្មានតំលៃលក់កាបូនឌីអុកស៊ីតប្រចាំឆ្នាំ គឺ ២.៦២២ដុល្លា/ហត។ អត្រាកំណើនការចាប់យកកាបូនឌីអុកស៊ីតប្រចាំឆ្នាំគឺមានចំនួន ១២៨,៧២តោន/ឆ្នាំ គិតជាលុយគឺអាចលក់បាន ៦៤៣.៦១ ដុល្លា/ឆ្នាំ ។

ធនធានព្រៃឈើនឹងត្រូវបាត់បង់ដោយសារគំរោងគឺ ៤.០៨០,១១ម$^{៣}$ នៃមាឌឈើឈរ ដែលមានតំលៃសរុប **១៨៥.៨៧៩,៣២ដុល្លា**។ បាត់បង់ឈើដោយសារគំរោង ២២.៥៦៩ដើម ដោយមានចំនួនជីវម៉ាសសរុប ៦.៥៧៨តោន បាត់បង់សមត្ថភាពស្រូបកាបូនឌីអុកស៊ីត ២៤.១១៩.១៨តោន/ឆ្នាំ ដែលមានតំលៃប៉ាន់ស្មាន **១២០.៥៩៦.៨២ដុល្លា/ឆ្នាំ**។ កំណើនមាឌឈើពាណិជ្ជកម្មប្រចាំឆ្នាំគឺ ៤០,០២ម$^{៣}$ ក្នុងនោះគិតជាតំលៃគឺ **១.៨២៤,៨២ដុល្លា/ឆ្នាំ** ហើយកំនើនជីវម៉ាសប្រចាំឆ្នាំរបស់ឈើពាណិជ្ជកម្មមានចំនួន ៦៤,០៣តោន ដែលកំនើននៃការស្រូបកាបូនឌីអុកស៊ីតប្រចាំឆ្នាំ ពីឈើពាណិជ្ជកម្មមានចំនួន ១៦.៦៥តោន ដែលមានតំលៃប៉ាន់ស្មាន **៣០៥,២២ ដុល្លារអាមេរិក/ឆ្នាំ**។

Draft

**<u>ការអង្កេតប្រភេទសត្វព្រៃ</u>**

យោងទៅតាមការអង្កេត និងការសំភាសន៍ជាក់ស្តែង គេអាចសន្និដ្ឋានបានថា យ៉ាងហោចណាស់មានសត្វព្រៃចំនួន ៨៧ប្រភេទ ដែលត្រូវបានរកឃើញនៅលើកោះពស់។ មានពពួកថនិកសត្វចំនួន ១១ប្រភេទ ថ្នាក់បណ្តុកសត្វ ៥ប្រភេទ ថ្នាក់ឧរង្គសត្វចំនួន ២៣ប្រភេទ និងថ្នាក់បក្សីចំនួន ៤៨ប្រភេទ។

ដោយពិនិត្យលើផ្នែកច្បាប់នៃប្រទេសកម្ពុជា ការពិព័ណ៌នាប្រភេទសត្វភាគច្រើនដែលបានរៀបរាប់មកនេះ គឺជាប្រភេទសត្វដែលសំបូរជាធម្មតា លើកលែងតែប្រភេទសត្វមួយចំនួនដែលត្រូវបានគេចំណាត់ថ្នាក់ជាប្រភេទសត្វកំរ មានដូចជា ពស់វែកក្របី អកសមុទ្រ សេកសោម ព្រាបកោះ ឥន្ទ្រីយ៏ ខ្លែងខ្មៅ។ ប្រភេទសត្វមួយចំនួនគឺមាននៅក្នុងបញ្ជីក្រហមនៃ IUCN ដែលសត្វទាំងនោះមានដូចជា ប្រូម៉ា ឥន្ទ្រីយ៏ ប្រចៀវ និងព្រាបកោះ។

ដោយឡែក សត្វព្រៃនៅក្នុងតំបន់គឺមិនមានតំលៃសេដ្ឋកិច្ចខ្ពស់ទេ ដោយតំលៃផ្ទាល់នៃសត្វនីមួយៗ។ សត្វទាំងនោះ ត្រូវបានគេប្រើប្រាស់សំខាន់ជាលក្ខណៈប្រពៃណីដោយប្រជាជនមូលដ្ឋានដោយធ្វើការបរបាញ់យូរៗ

ម្តង។ ប្រភេទសត្វដែលមានតំលៃខ្ពស់ សំរាប់ភ្ញៀវទេសចរណ៍ គឺពពួកសត្វស្វាក្តាម កេងកងតូច ឥន្ទ្រីយ៍ កំប្រុកពណ៌សត្វអកសមុទ្រ និងសត្វបក្សីដទៃទៀត។

ដោយសារតែជំរកសត្វព្រៃនៅលើកោះតូចទំហំដីតែ ១១៦,៣៦ហិកតា និងដោយសារការរំខានពីសកម្មភាពរបស់មនុស្ស ធ្វើឱ្យសត្វព្រៃនៅតំបន់នេះមានការធ្លាក់ចុះជាលំដាប់។ សត្វបក្សីមួយចំនួនធំមិនមានជំរកស្នាក់នៅជាអចិន្ត្រៃយ៍នៅតំបន់នេះទេ សត្វទាំងនោះមកទីនេះតាមរដូវកាលដើម្បីរកចំណីតែប៉ុណ្ណោះ។

- **តំបន់ការពារ**

ឧទ្យានជាតិរាម គឺស្ថិតនៅក្នុងឃុំរាម ស្រុកព្រៃនប់ និងតំបន់អភិរក្សទីជំរាលក្បាលឆាយ គឺស្ថិតនៅក្នុងឃុំអូរត្រេះ ស្រុកស្ទឹងហាវ។ ផ្អែកទៅលើផែទីតំបន់ការពាបានបង្ហាញថា ឧទ្យានជាតិរាមតាំងនៅភាគអាគ្នេយ៍នៃទីតាំងគំរោងដោយមានចំងាយ៦គ.ម។

## ៣.៣. ធនធានសេដ្ឋកិច្ចសង្គម

- **ប្រជាជន**

ដោយសារតែមានការរីកចំរើនសេដ្ឋកិច្ចនៅក្នុងប្រទេស ការអភិវឌ្ឍកំពង់ផែ ការអភិវឌ្ឍទេសចរណ៍ និងសកម្មភាពអភិវឌ្ឍន៍ផ្សេងៗទៀត នៅក្នុងខេត្តព្រះសីហនុដែលជាកត្តាសំខាន់នៃចំណូលស្រុកនៃប្រជាជនថ្មីមកក្នុងតំបន់ឆ្នេរនេះ។ ផ្អែកទៅលើជំរឿនប្រជាជនទូទៅរបស់ប្រទេសកម្ពុជាឆ្នាំ២០០៨ ក្នុងខែសីហា ឆ្នាំ២០០៩ បានបង្ហាញថា :

- ចំនួនប្រជាជនសរុបក្នុងខេត្តព្រះសីហនុគឺមាន ២២១.៣៩៦នាក់។
- ចំនួនប្រជាជនសរុបនៅក្នុងក្រុងព្រះសីហនុមាន ៩១.២៨៤នាក់។
- ចំនួនប្រជាជនសរុបនៅក្នុងសង្កាត់លេខ៣ដែលជាតំបន់ទីតាំងគំរោងតាំងនៅមាន ១៦.៦៣២នាក់។

- **ជនជាតិ និងសាសនា**

ក្នុងខេត្តព្រះសីហនុ មានក្រុមជនជាតិកំពុងរស់នៅ និងធ្វើការជាអ្នកនេសាទ អ្នកបច្ចេកទេស កសិករ អ្នកជំនួញខ្នាតតូច។ល។ ជនជាតិចំបងគឺ ខ្មែរ (៩៧%) ក្រៅពីនេះមានជនជាតិចាម វៀតណាម និងជនជាតិមកពីទ្វីបអឺរ៉ុបរស់នៅតំបន់នេះដែរ។

- **ការងារ**

ដោយសារតែធនធានធម្មជាតិ និងធនធានសង្គមនៅក្នុងតំបន់ឆ្នេរនេះ របរអចិន្ត្រៃយ៍របស់ប្រជាជនគឺជាអ្នកនេសាទ អ្នកជំនួញខ្នាតតូច និងជាកម្មករសំណង់។ ជាក់ស្តែង តាមលទ្ធផលស្រាវជ្រាវ ក្នុងខែកក្កដា ឆ្នាំ២០០៩



Draft

បានរកឃើញថាមុខរបរចំបងនៃអ្នកផ្តល់បទសំភាសន៍ទាំង២២៦នាក់គឺ ៣៥.៨%ជាអ្នកនេសាទ ១៦.៤%ជាអ្នកជំនួញខ្នាតតូច ១១.៥%ជាកម្មករក្នុងក្រុមហ៊ុនឯកជន/រោងចក្រ ១១.៥%ជាបុគ្គលិករដ្ឋ ១០.៦%ជាកម្មករសំណង់ ៤%ជាកម្មករកំពង់ផែ ៣.៥%ជាអ្នករត់ម៉ូតូឌុប/តាកស៊ី ១.៨%ជាអ្នកផ្តល់សេវាកម្មដឹកជញ្ជូន និង ៥.៨%មានមុខរបរផ្សេង១ទៀត។

- **ប្រាក់ចំណូល**

ប្រជាជននៅក្នុងតំបន់គំរោងគឺ រកប្រាក់ចំណូលពីមុខរបរផ្សេង១ពីគ្នា។ ប្រាក់ចំណូលត្រូវបានគេរកឃើញថាប្រភពចំណូលខ្ពស់របស់ប្រជាជននៅក្នុងតំបន់គំរោងគឺបានមកពីការនេសាទ(៣៨៥ដុល្លា/ខែ) និងសេវាកម្មដឹកជញ្ជូន (៣០៦ដុល្លា/ខែ)។ មុខរបរដែលជាប្រភពប្រាក់ចំណូលទាប គឺកម្មករសំណង់ (ប្រាក់ចំណូលជាមធ្យមប្រចាំខែ ៤៣៦.០០០រៀល/ខែឬ១០៩ដុល្លា/ខែ) និងបុគ្គលិករដ្ឋ(ប្រាក់ចំណូលជាមធ្យមប្រចាំខែគឺ ៣៩៦.០០០រៀល/ខែ ឬ៩៩ដុល្លា/ខែ)។

ការសិក្សាក្នុងតំបន់គោលដៅនៅក្នុង ភូមិ១ ភូមិ២ និងភូមិ៣ ជាមួយនឹងអ្នកផ្តល់ចំលើយចំនួន ២២៦គ្រួសារ បានបង្ហាញឱ្យដឹងថា គ្រួសារដែលមានលទ្ធភាពអាចរកប្រាក់ក្នុង១ខែមានគំលាតខុសគ្នារវាងអតិបរិមា និងអប្បបរមា ដោយផ្អែកទៅលើមុខរបររបស់ពួកគេ និងចំនួនសមាជិករកប្រាក់ចំណូលនៅក្នុងគ្រួសារនីមួយ១។ ការស្រាវជ្រាវបានបង្ហាញថា ប្រាក់ចំណូលប្រចាំខែរបស់គ្រួសារគឺ ៣៥៧ដុល្លា ប៉ុន្តែប្រាក់ចំណូលប្រចាំខែជាមធ្យមសំរាប់មនុស្សម្នាក់១ គឺ ៧១ដុល្លា តែប៉ុណ្ណោះ។

- **ដីប្រើប្រាស់ និងម្ចាស់កម្មសិទ្ធិ**

ក្រុងព្រះសីហនុមានផ្ទៃដីសរុបចំនួន ១៨៩.៣៩៩ គម $^{២}$ ឬ ១៨.៩៣៩.៩ ហត ដែលរួមមានសង្កាត់ មួយ ពីរ បី បួន និងសង្កាត់កោះរ៉ុង ហើយបានបែងចែកទៅជា ដីព្រៃ ដីកសិកម្ម ដីលំនៅដ្ឋាន និងផ្ទៃដីដទៃទៀត។

តាមការអង្កេតស្រាវជ្រាវបានរកឃើញថា ៧៤គ្រួសារ ឬ៣២.៧% នៃគ្រួសារដែលបានឆ្លើយតប ដីលំនៅដ្ឋានផ្ទាល់របស់ពួកគេមានប្លង់កម្មសិទ្ធពេញលេញ តែ១១៥គ្រួសារ ឬស្មើនឹង៥០.៩%មានឯកសារបញ្ជាក់ពីអាជ្ញាធរស្រុក និងឃុំតែប៉ុណ្ណោះ ហើយនិង ៣៧គ្រួសារ ឬ១៦.៤% គ្រាន់តែបានទទួលស្គាល់ពីអាជ្ញាធរថ្នាក់ភូមិនៅលើដីរបស់ពួកគាត់ដោយគ្មានឯកសារបញ្ជាក់ពីសិទ្ធកាន់កាប់នោះទេ។

- **ការផ្គត់ផ្គង់ទឹក**

បណ្តាញទឹកស្អាតក្រុងព្រះសីហនុ បានគ្របដណ្តប់ប្រហែល ៤៧% នៃចំនួនគ្រួសារសរុបនៅក្នុងក្រុងទាំងមូល ចំណែក១២%បានប្រើប្រាស់ទឹកអណ្តូងស្នប់ និង៣១%ប្រើប្រាស់អណ្តូងលូ។ សមត្ថភាពនៃរោងចក្រទឹកស្អាតក្រុងអាចផលិតបានចំណុះ ៨.០០០ម $^{៣}$ ក្នុង១ថ្ងៃ ក៏ប៉ុន្តែដោយសារបណ្តាញចែកចាយទឹកមានកំណត់ ហេតុដូច្នេះហើយ ការផលិតទឹកស្អាតដើម្បីផ្គត់ផ្គង់ទឹកក្នុងក្រុងព្រះសីហនុមានតែ ៥.០០០ម $^{៣}$ ក្នុង១ថ្ងៃ។ ប្រភពទឹកស្អាតពីរកន្លែង



Draft

ត្រូវបានប្រើប្រាស់សំរាប់ផ្គត់ផ្គង់រោងចក្រទឹកស្អាត គឺបឹងព្រៃកទប់ និងព្រៃកក្បាលឆាយ។ បណ្តាញផ្គត់ផ្គង់ទឹកស្អាតក្រុងព្រះសីហនុត្រូវបានដំណើរការ២៤ម៉ោងក្នុង១ថ្ងៃ និងមានគុណភាពទឹកផ្អែកទៅតាម បទដ្ឋានទឹកផឹកនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល របស់រាជរដ្ឋាភិបាលកម្ពុជា។

តម្លៃទឹកស្អាតរបស់រដ្ឋាករទឹកគឺ ១៥០០រៀល/ម$^{៣}$ ឬ០.៣៦ដុល្លា/ម$^{៣}$។ ទោះជាយ៉ាងណាក៏ដោយ តម្លៃនេះនឹងឡើងខ្ពស់ជាងនេះ ប្រសិនបើពួកគេប្រើលើសពី៧ម៉ែត្រគូប។

- **ប្រព័ន្ធអនាម័យ**

ប្រព័ន្ធអនាម័យមជ្ឈដ្ឋានត្រូវបានកែលំអនៅក្នុងក្រុងព្រះសីហនុ ប្រព័ន្ធអាងប្រព្រឹត្តិកម្មទឹកក្រខ្វក់ដោយប្រើប្រាក់កម្ចីពីធនាគារអភិវឌ្ឍន៍អាស៊ី ដែលមានសមត្ថភាពសំអាតបាន ៦,៩០០ម$^{៣}$/ថ្ងៃ ត្រូវបានសាងសង់រួចរាល់ជាស្ថាពរ ហើយបានដាក់ឱ្យប្រើប្រាស់នៅក្នុងខែសីហាឆ្នាំ២០០៦។ ប្រព័ន្ធដោះទឹកក៏ត្រូវបានកែលំអដោយមូលនិធិក្រុងផងដែរ។ ដោយឡែក សំរាប់លំនៅដ្ឋាននីមួយៗ និងអាគារពាណិជ្ជកម្មនានាមានបង្គន់អនាម័យ និងអាងសិបទិកផ្ទាល់ខ្លួនរបស់ពួកគេ ហើយយោងទៅតាមទិន្នន័យដែលទទួលបានពីមន្ទីរផែនការបានបង្ហាញឱ្យដឹងថា នៅក្នុងក្រុងព្រះសីហនុមានអត្រាប្រើប្រាស់បង្គន់អនាម័យខ្ពស់ គឺ ៧៤.៧% បើប្រៀបធៀបទៅនឹងស្រុកដទៃទៀតក្នុងខេត្តនេះ។

ការគ្រប់គ្រងកាកសំណល់រឹងនៅក្នុងក្រុងព្រះសីហនុបានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនឯកជន "សាខាក្រុមហ៊ុនស៊ិនទ្រី" ដើម្បីធ្វើការប្រមូល ដឹកជញ្ជូន និងបោះចោលក្នុងទីលានចាក់សំរាមនៅខាងក្រៅក្រុង (នៅក្នុងឃុំបិតត្រាង, ស្រុកព្រៃនប់) ដែលមានចំងាយ២០គីឡូម៉ែត្រភាគខាងកើតក្រុង។ មានចំនួនប្រហែល៨៥%នៃចំនួនគ្រួសារទាំងអស់នៅក្នុងក្រុងបានទទួលសេវាកម្មប្រមូលសំរាមនេះ។

ទោះជាយ៉ាងណាក៏ដោយ តំបន់នៅតាមបណ្តោយឆ្នេរគឺមិនបានគ្របដណ្តប់ដោយសេវាកម្មប្រមូលសំរាមនោះទេ ហើយសំរាមទាំងអស់នៅក្នុងតំបន់នោះត្រូវបានប្រមូលដោយអ្នកលក់ដូរនៅហ្នឹងកន្លែងផ្ទាល់។ នៅក្នុងអំឡុងពេលសិក្សាការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ក្រុមសិក្សារបស់ឃីខនសាល់ធេនខេមបូឌា (KCC) បានធ្វើការប្រមូលសំរាមនៅក្នុងតំបន់សិក្សា (តាមបណ្តោយឆ្នេរហាវ៉ៃ និងតំបន់ឆ្នេរជុំវិញកោះពស់)។ រយៈពេលប្រមូលសំរាម គឺមានរយៈពេល៨ថ្ងៃ (១០-១៧ ខែមិថុនា ឆ្នាំ២០០៩) ថ្ងៃទី១ត្រូវបានប្រមូលចោល(ថ្ងៃសំអាត)។ ជាលទ្ធផលនៃការប្រមូលសំរាមលើឆ្នេរខ្សាច់ក្នុងតំបន់គំរោងបានបង្ហាញថា សំរាមជាមធ្យមដែលបានកើតមាន ឡើងនៅលើឆ្នេរហាវ៉ៃ និងជុំវិញតំបន់កោះពស់គឺ មានទំងន់ ៨៨ គីឡូក្រាម និង ៩៣គីឡូក្រាម។ ស្លឹកឈើ និងមែកឈើមានចំនួនច្រើន ហើយបន្ទាប់មក គឺសំរាមប្លាស្ទិក។

- **ការផ្គត់ផ្គង់ថាមពលអគ្គិសនី**

តាមរបាយការណ៍អំពីផែនការសកម្មភាពអភិវឌ្ឍន៍នៃខេត្តព្រះសីហនុឆ្នាំ២០០៩-២០១៣ បានបង្ហាញថា មានគ្រួសារចំនួន៩៥% នៅក្នុងក្រុងព្រះសីហនុបានទទួលប្រព័ន្ធថាមពលអគ្គិសនី។

Draft

ជាងនេះទៅទៀតតាមទិន្នន័យដែលទទួលបានពីសាខាអគ្គិសនីកម្ពុជាក្រុងព្រះសីហនុថ្ងៃទី៣០ ខែមីនា ២០១០ បានបង្ហាញថា មានគ្រួសារ ១០០% នៅក្នុងខ័ណ្ឌមិត្តភាពពីមុនបានប្រើប្រាស់ភ្លើងអគ្គិសនី។ បច្ចុប្បន្ននេះ តំរូវការប្រើប្រាស់ថាមពលអគ្គិសនីអស់១០មេហ្គាវ៉ាត់ ឯសមត្ថភាពផលិតសរុបគឺ១៥មេហ្គាវ៉ាត់ ក្នុងនោះ១០មេហ្គាវ៉ាត់ទទួលបានពីអ្នកផលិតថាមពលឯករាជ្យ និង៥មេហ្គាវ៉ាត់ទៀតបានមកពីអគ្គិសនីកម្ពុជា។

តម្លៃប្រើប្រាស់អគ្គិសនី ៧២០រៀល/គីឡូវ៉ាត់ម៉ោង (តម្លៃធម្មតា) ឬ០.១៨ដុល្លា/ គីឡូវ៉ាត់ម៉ោង។ ប៉ុន្តែតម្លៃទទួលបានពីអ្នកប្រើប្រាស់ទីពីរ(តពីផ្ទះអ្នកជិតខាង)តម្លៃអគ្គិសនីខុសគ្នាពី១០០០-២០០០រៀល/ គីឡូវ៉ាត់ម៉ោង (០.២៥-០.៥/ គីឡូវ៉ាត់ម៉ោង)។ ប្រជាជនស្ទើរតែទាំងអស់នៅក្នុងតំបន់គំរោងប្រើប្រាស់ថាមពលសំរាប់ បំភ្លឺ ចំអិនអាហារ ទូរទឹកកក ក្ងាសេ និងប្រើប្រាស់ក្នុងគោលបំណងផ្សេងទៀត។ គ្រួសារមួយចំនួនប្រើប្រាស់អុស និងធ្យូងសំរាប់ចំអិនអាហារផងដែរ។

- **ឧស្សាហកម្ម**

មានរោងចក្រចំនួន ២៤រោងចក្រ និងសិប្បកម្ម១៥៨កន្លែង នៅក្នុងខេត្តព្រះសីហនុក្នុងពេលបច្ចុប្បន្ននេះ ក្នុងតួរលេខខាងលើនេះ មាន១៦កន្លែង ឬស្មើនឹង ៦៧% ស្ថិតនៅក្នុងក្រុងព្រះសីហនុ។ ប៉ុន្តែមាន១៣រោងចក្រ ក្នុងចំណោមរោងចក្រ ទាំងអស់នៅក្នុងក្រុងព្រះសីហនុបានកំពុងដំណើរការ ដែលក្នុងនោះមាន១រោងចក្រស្ថិតនៅក្នុងសង្កាត់លេខបី។ សព្វថ្ងៃនេះ មានរោងចក្រឧស្សាហកម្មមួយចំនួនត្រូវបានសាងសង់នៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ស្ថិតនៅក្នុង ឃុំបិតត្រាំង ស្រុកព្រៃនប់ និងក្នុងតំបន់ឧស្សាហកម្មក្នុងសង្កាត់១ នៃខ័ណ្ឌមិត្តភាព។ ក្រៅពីនេះ មានរោងចក្រផលិតថាមពលអគ្គិសនីដើរដោយធ្យូងថ្មចំនួនពីរ ដោយមានអានុភាពនីមួយៗគឺ ១០០មេហ្គាវ៉ាត់ ដែលកំពុងសាងសង់នៅក្នុងស្រុកស្ទឹងហាវ។

- **ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន**

<u>**បណ្តាញផ្លូវថ្នល់**</u>

ផ្លូវថ្នល់សំខាន់ៗភាគច្រើននៅក្នុងខេត្តត្រូវបានកែលំអ និងសាងសង់ ឧទាហរណ៍ ផ្លូវជាតិលេខ៤ និងលេខ៣ គឺវិថីសម្តេចហ៊ុន សែន និងផ្លូវសម្តេចទេពវង្ស។ ទន្ទឹមនេះដែរ ប្រព័ន្ធផ្លូវថ្នល់រួមមានផ្លូវថ្នល់ បណ្តាញលូនៅក្នុងក្រុងព្រះសីហនុត្រូវបានកែលំអ និងថែទាំដោយមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត ជាពិសេស នៅក្នុងខ័ណ្ឌមិត្តភាព។ ជាងនេះទៅទៀត មន្ទីរសាធារណការ និងដឹកជញ្ជូនមានផែនការដើម្បីធ្វើការកែលំអ/ពង្រីក និងសាងសង់ផ្លូវមួយចំនួននៅក្នុងខ័ណ្ឌមិត្តភាព។

<u>**កំពង់ផែ**</u>

កំពង់ផែសមុទ្រអន្តរជាតិធំបំផុតរបស់ប្រទេសកម្ពុជា គឺកំពង់ផែក្រុងព្រះសីហនុ ឬកំពង់ផែកំពង់សោមស្ថិតនៅក្នុងក្រុងព្រះសីហនុ និងមានចំងាយប្រហែល២គ.ម ភាគពាយ័ព្យនៃតំបន់គំរោង**មរកត**។ នៅពេលថ្មីៗនេះ កំពង់ផែ

Draft

គឺមានសកម្មភាពមមាញឹកណាស់ ដោយសារការរីកចំរើននៃសេដ្ឋកិច្ច កប៉ាល់ដឹកទំនិញបានឆ្លងកាត់កំពង់ផែនេះបានកើនឡើង និងមានអ្នកទេសចរណ៍អន្តរជាតិបានធ្វើដំណើរតាមកប៉ាល់ ក៏បានចាប់ផ្តើមចូលចតនៅទីនេះពី១ដង ទៅ២ដងក្នុងមួយខែ។ កំពង់ផែនេះ កំពុងប្រតិបត្តិការក្នុងលក្ខខណ្ឌស្វយ័តក្រោមការគ្រប់គ្រងដោយអាជ្ញាធរកំពង់ផែក្រុងព្រះសីហនុ និងក្រសួងសាធារណការ និងដឹកជញ្ជូន។ ជាមធ្យមកប៉ាល់ផ្ទុកទំនិញចំនួន២បានចូលចំណតក្នុង១ថ្ងៃក្នុងមួយសប្តាហ៍ ប៉ុន្តែមានពេលខ្លះកប៉ាល់ដឹកទំនិញចំនួន៤ក្នុង១ថ្ងៃបានចូលចត (ថ្ងៃសុក្រ និងថ្ងៃសៅរ៍) ទៅតាមតំរូវការក្រុមហ៊ុនដឹកជញ្ជូនតាមនាវា។

**<u>អាកាសយានដ្ឋាន</u>**

អាកាសយានដ្ឋានកងកេង គឺស្ថិតនៅក្នុងឃុំរាម ស្រុកព្រៃនប់ ដែលមានចំងាយប្រហែល១៨គ.ម ប៉ែកអាគ្នេយពីចំនុចកណ្តាលនៃក្រុងព្រះសីហនុ។ វាជាអាកាសយាដ្ឋានអន្តរជាតិទី៣នៃប្រទេសកម្ពុជា ដែលត្រូវបានកសាងដំបូងឡើងនៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ដោយជំនួយពីសហភាពសូវៀត។ អាកាសយានដ្ឋាននេះត្រូវបានស្តារ និងបើកប្រតិបត្តិការឡើងវិញនៅក្នុងថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៧ ទោះជាយ៉ាណាក៏ដោយ យន្តហោះប្រភេទតូច និងមធ្យមរួមទាំងយន្តហោះប្រតិកម្មបូអ៊ីង ៧៣៧ អាចចុះចតផងដែរ។

- **ការអប់រំ**

វិស័យអប់រំត្រូវបានកំពុងកែលំអគ្រប់ទីកន្លែងនៅទូទាំងប្រទេស។ កំរិតអប់រំ និងអត្រាអ្នកចេះអក្សរក្នុងចំនួនស្ត្រីសរុប ជាទូទៅមានចំនួនតិចជាងបុរស ពោលគឺ ស្ត្រី៦៧% ហើយបុរស៨២%។ ផ្អែកតាមសំយោគឯកសារនៃសៀវភៅកំរងទិន្នន័យស្ថិតិកម្ពុជាប្រចាំឆ្នាំ២០០៨បានឱ្យដឹងថា សាលាចំណេះទូទៅមានការកើនឡើងជាលំដាប់ ដូចគ្នានេះដែរនៅក្នុងខេត្តព្រះសីហនុមានកំនើនសាលាចំណេះទូទៅផងដែរមកដល់ឆ្នាំ២០០៨។ ជាក់ស្តែងក្នុងចំនួន៣ភូមិ នៃសង្កាត់លេខ៣ ក្នុងក្រុងព្រះសីហនុបានបញ្ជាក់ថា អ្នកឆ្លើយតបមានអាយុពី១៨ទៅ៧៤ឆ្នាំ គឺជាមេគ្រួសារ ហើយកំរិតវប្បធមិរបស់ពួកគេទាំងនោះគឺ មិនចេះអក្សរ(២៤.៣%) បឋមសិក្សា(៤០.៣%) អនុវិទ្យាល័យ(២៥.៧%) និងវិទ្យាល័យ(៨.៤%) ហើយនិងកំរិតឧត្តមសិក្សា ឬក៏លើសពីនេះ(១.៣%)។

- **សុខភាព**

សេវាកម្មសុខភាព គឺមានភាពងាយស្រួលនៅក្នុងទីក្រុង ទីរួមខេត្ត ទីរួមស្រុក ទោះជាយ៉ាងណាក៏ដោយមណ្ឌលសុខភាពមួយចំនួនមាននៅក្នុងឃុំផងដែរ។ នៅក្នុងក្រុងព្រះសីហនុមានមន្ទីរពេទ្យបង្អែកមួយ ដែលមានបុគ្គលិក ពេទ្យសរុប ១៤៥នាក់ ក្នុងនោះ ២៩នាក់ ជាវេជ្ជបណ្ឌិត(កំរិតខ្ពស់) និង៧៩នាក់ ជាគ្រូពេទ្យ(កំរិតមធ្យម) និង១៨នាក់ ជាគិលានុបដ្ឋាក(កំរិតទាប)។ នៅពេលបច្ចុប្បន្ននេះ ផលប៉ះពាល់សុខភាពភាគច្រើនទៅដល់អ្នកស្រុក គឺជំងឺប្រព័ន្ធ ដង្ហើម និងជំងឺរាគធម្មតា។

Draft

- **ទេសចរណ៍**

ក្នុងពេលបច្ចុប្បន្ននេះ ក្រុងព្រះសីហនុបានក្លាយទៅជាប៉ូលអភិវឌ្ឍន៍ទេសចរណ៍ទី២នៃប្រទេសកម្ពុជា បន្ទាប់ពីក្រុងសៀមរាប។ ឆ្លើយតបទៅនឹងការកើនឡើងវិស័យទេសចរណ៍យ៉ាងឆាប់រហ័យក្នុងរយៈពេលពីរបីឆ្នាំចុងក្រោយនេះ ចំនួនសេវាកម្ម/ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ត្រូវបានអភិវឌ្ឍន៍ និងស្ថាបនាឡើងយ៉ាងច្រើន។ ផ្អែកតាមរបាយការណ៍ប្រចាំឆ្នាំ២០០៨ របស់មន្ទីរទេសចរណ៍ខេត្ត បានបញ្ជាក់ថា មានសណ្ឋាគារចំនួន៤៦ ក្នុងនោះមានបន្ទប់សរុបចំនួន១.៧៨២ បន្ទប់ ផ្ទះសំណាក់មាន១១១កន្លែង ក្នុងនោះមានបន្ទប់ចំនួន១.៥១៣បន្ទប់ ភោជនីយដ្ឋានមានចំនួន៧៧ ក្នុងនោះមាន តុចំនួន១.០៣១ និង៤.៥៥៤កៅអី កាស៊ីណូមាន៣កន្លែង ម៉ាស្សាមាន៧កន្លែង និងមានភ្នាក់ងារទេសចរណ៍ ៦កន្លែង។ សេវាកម្មទាំងអស់នេះ គឺមានដំណើរការជំនួញល្អណាស់ និងមានសណ្ឋាគារកំរិតខ្ពស់ជាច្រើនទៀត ( ផ្កាយ៣-៥) និងផ្ទះសំណាក់មួយចំនួនកំពុងសាងសង់ និងមានផែនការធ្វើជាបន្តបន្ទាប់។

ក្នុងឆ្នាំ២០០៨ អ្នកទេសចរណ៍សរុប ៥៣២.៥១៨នាក់ ក្នុងនោះ ៣៩៨.៨៥០នាក់ ជាអ្នកទេសចរណ៍អន្តរជាតិ និង១៣៥.៦៦៨នាក់ ជាអ្នកទេសចរណ៍ក្នុងស្រុក ហើយចំនួននេះ មានការកើនឡើង ៤០.២៥% បើប្រៀបធៀបទៅនឹង ឆ្នាំ២០០៧។ ភ្ញៀវក្នុងស្រុកមានការកើនឡើង ៣៨.៦៥% និងភ្ញៀវអន្តរជាតិមានការកើនឡើង ៤៥.១៤% ទន្ទឹមនោះដែរ អ្នកទេសចរណ៍ដែលមកតាមនាវាទេសចរណ៍អន្តរជាតិ មានចំនួន ១៤.១៥៩នាក់។

- **ធនធានវប្បធម៌ និងប្រវត្តិសាស្ត្រ**

គ្មានទីតាំងប្រវត្តិសាស្ត្រ ឬក៏ទីតាំងវត្ថុបូរាណស្ថិតនៅក្នុងតំបន់គំរោងនេះទេ លើកលែងតែវត្តអារាម២កន្លែងដែលស្ថិតនៅ ក្នុងសង្កាត់លេខ៣ និងសង្កាត់លេខ១ ក្នុងក្រុងព្រះសីហនុ។

## ៣.៤. សកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ច

ដោយសារតែមានធនធានធម្មជាតិដូចជា សមុទ្រ ត្រីទឹកប្រៃ ឆ្នេរខ្សាច់ដ៏ស្រស់ស្អាត កោះ ភ្នំ និងទឹកធ្លាក់នៅក្នុងតំបន់ បានផ្តល់នូវសក្តានុពលខ្ពស់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច។ វិស័យអភិវឌ្ឍន៍ជាច្រើន រួមមាន វិស័យទេសចរណ៍ កសិកម្ម ឧស្សាហកម្ម ការដឹកជញ្ជូន ពាណិជ្ជកម្មអន្តរជាតិ និងវិស័យផ្សេងៗទៀត។ វិស័យទេសចរណ៍ គឺបានចូលរួមចំណែកគួរឱ្យពេញចិត្តក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងក្រុងព្រះសីហនុក៏ដូចទូទាំងប្រទេស ការកើនឡើងអ្នកទេសចរណ៍ខ្ពស់ទាំងភ្ញៀវជាតិ និងភ្ញៀវអន្តរជាតិដែលបានមកលេង និងស្នាក់នៅក្នុងក្រុងព្រះសីហនុនៅក្នុងរយៈពេលពីរបីឆ្នាំចុងក្រោយនេះ។ ការកើនឡើងអ្នកទេសចរណ៍ អាចផ្តល់នូវការងារធ្វើយ៉ាងច្រើន និងប្រាក់ចំណូលទៅដល់ប្រជាជនមូលដ្ឋានទៀតផង។

វិស័យកសិកម្មត្រូវបានគេកត់សំគាល់ផងដែរថា អាហារសមុទ្រជាច្រើនប្រភេទនៅក្នុងប្រទេសកម្ពុជា គឺត្រូវបានគេប្រមូលផលចេញពីធនធានជលផលនៅក្នុងតំបន់ឆ្នេរ រួមទាំងខេត្តព្រះសីហនុ។ ផលិតផលនេសាទមានតំលៃមួយចំនួនត្រូវបានគេនាំចេញទៅក្រៅប្រទេសផងដែរ។

ការអភិវឌ្ឍវិស័យឧស្សាហកម្មនៅក្នុងខេត្តព្រះសីហនុ បានក្លាយទៅជាចំណាប់អារម្មណ៍យ៉ាងខ្លាំងទៅដល់អ្នកវិនិយោគ ពីព្រោះមានមធ្យោបាយដឹកជញ្ជូនគ្រប់គ្រាន់ ដូចជាកំពង់ផែ អាកាសយានដ្ឋាន ផ្លូវរថភ្លើង និងបណ្តាញផ្លូវថ្នល់។ តំបន់សេដ្ឋកិច្ចពិសេស២កន្លែងកំពុងបានសាងសង់ មួយនៅក្នុងតំបន់ជិតកំពង់ផែព្រះសីហនុ និងមួយផ្សេងទៀតស្ថិតនៅក្នុងឃុំបិតត្រាំង ក្នុងស្រុកព្រៃនប់។

កំពង់ផែកំពង់សោមមានភាពមមាញឹកណាស់ពីមួយថ្ងៃទៅមួយថ្ងៃ ដោយសារមានការកើនឡើងកប៉ាល់ដឹកទំនិញនាំចេញ និងនាំចូលសំរាប់ពាណិជ្ជកម្មអន្តរជាតិ។ ផ្អែកលើកំពង់ផែនេះ កម្ពុជាអាចពង្រីកទីផ្សារពាណិជ្ជកម្មទៅក្នុងពិភពលោកបាន។

## ៤. ការចូលរួមជាសាធារណៈ

ការចូលរួមជាសាធារណៈ គឺមានន័យយ៉ាងទូលំទូលាយ ផ្តល់ឱកាស ឬអនុញ្ញាតឱ្យសហគមន៍ និងប្រជាជន ឬគ្រួសារដែលរងផលប៉ះពាល់ដើម្បីចូលរួមក្នុងកិច្ចប្រជុំក្នុងការទទួលព័ត៌មានគំរោង និងសំណើសុំ/ផ្តល់មតិយោបល់នៅលើសកម្មភាពគំរោង។ ការចូលរួមជាសាធារណៈ គឺរួមទាំងការប្រជុំពិគ្រោះយោបល់ជាមួយអ្នកដែលពាក់ព័ន្ធ ឬក៏ស្ថាប័នសំខាន់ៗដែលមានការពាក់ព័ន្ធទៅនឹងសកម្មភាពគំរោង។ កិច្ចប្រជុំនេះ គឺជាផ្នែកមួយមានសារសំខាន់ណាស់ជួយធ្វើអន្តរាគមន៍នៅក្នុងការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដើម្បីអនុវត្តគំរោងឱ្យរលូន។

ក្រុមគោលដៅរបស់គំរោង នឹងត្រូវបានអញ្ជើញឱ្យចូលរួមដូចជា ប្រជាជនរងផលប៉ះពាល់ អាជ្ញាធរមូលដ្ឋាន សមាជិកសហគមន៍ មនុស្សសំខាន់ៗ និងអ្នកដែលពាក់ព័ន្ធផ្សេងៗទៀតដើម្បីចូលរួម និងស្វែងរកទស្សនៈរបស់ពួកគេទៅលើការអភិវឌ្ឍគំរោង។

Draft

### ៤.១ កិច្ចពិគ្រោះយោបល់ជាសាធារណៈ

កិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈត្រូវបានធ្វើឡើងពីរលើកក្នុងអំឡុងពេលសិក្សា វ.ហ.ប។ កិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈលើកទី១ គឺដើម្បីផ្តល់ព័ត៌មានគំរោងទៅដល់សហគមន៍មូលដ្ឋាន និងពិនិត្យមើលបញ្ហាបរិស្ថានដែលនឹងអាចកើតមានឡើងពាក់ព័ន្ធទៅនឹងសកម្មភាពរបស់គំរោង។ ការរៀបចំកិច្ចប្រជុំត្រូវបានធ្វើឡើងតាមរយៈអ្នកដឹកនាំក្នុងកំរិតថ្នាក់ឃុំ និងភូមិ។

កិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈលើកទី២ ត្រូវបានរៀបចំបន្ទាប់ពីការបញ្ចប់ការងារចុះសិក្សានៅទីវាលក្នុងតំបន់គំរោង និងប្រមូលបាននូវលទ្ធផលសិក្សាដ៏ត្រឹមត្រូវគ្រប់គ្រាន់ រួមទាំង ការរចនាប្លង់វិស្វកម្ម ការសិក្សា

វ.ហ.ប របស់គំរោង និងការសិក្សាផ្សេងៗទៀត ដើម្បីបង្ហាញទៅដល់អ្នកដែលពាក់ព័ន្ធ ។ តំណាងមកពីសហគមន៍ដែលរងផលប៉ះពាល់ គ្រប់មន្ទីរពាក់ព័ន្ធនៅក្នុងខេត្ត ផ្នែកឯកជន អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នផ្សេងទៀតមកពីភ្នំពេញដែលពាក់ព័ន្ធទៅនឹងគំរោងក៏ត្រូវបានអញ្ជើញឱ្យចូលរួមក្នុងកិច្ចប្រជុំនោះផងដែរ ។

លទ្ធផលនៃកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈដែលទទួលបានដូចជា ទស្សនៈ យោបល់ និងសំនួរ មានដូចខាងក្រោម :

- តើខ្ញុំអាចធ្វើការនេសាទនៅជុំវិញតំបន់កោះពស់បានដែរឬទេ ?
- តើគំរោងនឹងចាប់ផ្តើមសាងសង់នៅពេលណា ?
- តើខ្ញុំអាចចាប់ត្រីមួយចំនួននៅជុំវិញកោះបានដែរឬទេ ?
- តើយើងអាចចង/ចតទូកនេសាទត្រីនៅក្បែរតំបន់គោលដៅគំរោងបានដែរ ឬទេ ?
- បារម្ភលើបរិស្ថាន ពុំដឹងថាតើហេតុប៉ះពាល់បរិស្ថានមានយ៉ាងដូចម្តេច ?
- សូមអនុញ្ញាតឱ្យអ្នកភូមិរបស់យើងនេសាទត្រី នៅជុំវិញតំបន់កោះពស់នេះផង
- សំណូមពរដល់ម្ចាស់គំរោង សុំផ្តល់ការងារធ្វើដល់ប្រជាជនក្នុងមូលដ្ឋានក្នុងអំឡុងពេលសាងសង់គំរោង ធ្វើជាកម្មករ ឬបុគ្គលិកនៅក្នុងក្រុមហ៊ុន ។
- សំណូមពរដល់ម្ចាស់គំរោង សុំផ្តល់ការងារធ្វើដល់ប្រជាជនក្នុងមូលដ្ឋានឱ្យបានច្រើនក្នុងអំឡុងពេលសាងសង់គំរោង ។
- អ្នកប្រើប្រាស់ស្ពានទាំងអស់ មិនបង់លុយក្នុងការឆ្លងកាត់ទេ ។
- សំណូមពរដល់ម្ចាស់គំរោង សុំផ្តល់កន្លែងសុវត្ថិភាពដល់អ្នកនេសាទត្រីក្នុងការចតទូកនេសាទនៅពេលដែលពួកគេជួបព្យុះ ឬភ្លៀងធំ ។
- សំណូមពរដល់ម្ចាស់គំរោង សូមអនុញ្ញាតដល់ប្រជាជនខ្មែរទៅទស្សនាក្នុងតំបន់កំសាន្ត នៅក្នុងតំបន់ដោយគ្មានការហាមឃាត់ដូចជាឆ្នេរសុខាឡើយ ។
- ប្រជាជនមួយចំនួនធំនៅក្នុងភូមិគឺជាកម្មករសំណង់ ដូច្នេះសុំសំណូមពរឱ្យក្រុមហ៊ុនធ្វើការជ្រើសរើសយកកម្មករនៅក្នុងភូមិ ជាពិសេសនៅក្នុងភូមិបីផង ។
- មានការសប្បាយចិត្តជាមួយគំរោងនេះណាស់ ពីព្រោះវាជាពេលវេលាដ៏ល្អមួយសំរាប់ការបង្កើនការងារ បង្កើនវិស័យទេសចរណ៍ និងធ្វើឱ្យប្រសើរឡើងនូវគុណភាពជីវិតរបស់ប្រជាជន ជាពិសេសប្រជាជនដែលរស់នៅក្នុងតំបន់ ។

សំនួរភាគច្រើនត្រូវបានឆ្លើយតបដោយក្រុមអ្នកសិក្សាបន្ទាប់ពីសួរសំនួរនីមួយៗ ។ ប្រជាជនមានការយល់ដឹងច្រើនពីគំរោង និងសកម្មភាពរបស់វា ។ ជាទូទៅ អ្នកចូលរួមនៅក្នុងសង្កាត់លេខ៣ បានគាំទ្រគំរោង១០០% និងចង់ឱ្យ



Draft

គំរោងដំណើរការក្នុងពេលឆាប់ៗ។ ដោយផ្អែកទៅលើការសិក្សាស្រាវជ្រាវ បានរកឃើញថា អ្នកចូលរួមទាំងអស់នៅក្នុងពាភូមិ បានយល់ព្រមចំពោះការអភិវឌ្ឍគំរោងនេះ ។

## ៤.២ ការប្រជុំជាមួយអ្នកដែលពាក់ព័ន្ធ

អន្តរទំនាក់ទំនងជាមួយនឹងស្ថាប័នដែលពាក់ពន្ធ័សំខាន់ៗ គឺជាកត្តាដ៏សំខាន់បំផុតសំរាប់គំរោងអភិវឌ្ឍន៍ ដូចជា មន្ទីរស្ថាប័នរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន អង្គការក្រៅរដ្ឋាភិបាល និងផ្នែកឯកជន ក៏ត្រូវបានពិគ្រោះយោបល់ និងពិភាក្សានៅ ក្នុងការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថានសំរាប់គំរោងមរកតនៃក្រុមហ៊ុនវិនិយោគកោះពស់ ។

លទ្ធផលនៃកិច្ចប្រជុំ និងពិគ្រោះយោបល់ជាមួយអ្នកដែលពាក់ព័ន្ធបានចង្អុលបង្ហាញថា ពួកគេបានគាំទ្រគំរោង១០០% និងបានសន្យាធ្វើកិច្ចសហប្រតិបត្តិការ និងសំរបសំរួលគ្រប់ការងារដែលពាក់ពន្ធ័ជាមួយក្រុមហ៊ុនកោះពស់ ។ គំរោងនេះនឹងផ្តល់ការងារបន្ថែមទៀតដល់ប្រជាជន និងប្រាក់ចំណូលនៅក្នុងខេត្តព្រះសីហនុ ។

ទោះជាយ៉ាងណាក៏ដោយ ពួកគេទាំងនោះបានស្នើសុំទៅម្ចាស់គំរោងឱ្យរៀបចំវិធានការបន្ធូរបន្ថយមានដែលចំណុចសំខាន់ៗដូចខាងក្រោម :

- អនុវត្តតាមផែនការមេនៃគំរោង និងអនុលោមតាមផែនការមេរបស់ទីក្រុង ។
- បង្កើតគណៈកម្មការត្រួតពិនិត្យគំរោង ។
- ដឹកជញ្ជូនកាកសំណល់រឹង នៅក្នុងពេលយប់ មិនត្រូវរំខានដល់អ្នកជិតខាង ។
- ផ្តល់នូវប្រពន្ធ័រំដោះទឹកឱ្យបានគ្រប់គ្រាន់ ។
- ដាំដើមឈើឡើងវិញ និងអភិរក្សសត្វព្រៃដែលមានស្រាប់នៅលើកោះ និងត្រួតពិនិត្យនូវកាកសំណល់រឹង និងកាកសំណល់រាវឱ្យបានល្អត្រឹមត្រូវ ។
- ធ្វើការត្រួតពិនិត្យធនធានបរិស្ថានជាទៀងទាត់ក្នុងអំឡុងពេលអនុវត្តន៍គំរោងទាំងមូល ។
- បំពាក់ប្រពន្ធ័ឧបករណ៍កែច្នៃកាកសំណល់ និងធ្វើប្រព្រឹត្តិកម្មសំអាតកាកសំណល់រាវមុនបង្ហូរចេញទៅក្នុងសមុទ្រ ។
- ការពារនូវការហូរច្រោះដី និងល្បាប់ភក់ហូរចូលទៅក្នុងទឹកដែលអាចបង្កឱ្យមានការខូចខាតដល់ធនធានផ្កាថ្ម និងត្រី និងធ្វើឱ្យរាក់ឃ្លងធម្មជាតិដែលជាផ្លូវនាវាចរណ៍សំខាន់មួយចំពោះកំពង់ផែ ។
- គ្រប់សកម្មភាពសាងសង់ និងការបង្ហូរចេញនូវកាកសំណល់ត្រូវតែគោរពតាមបទដ្ឋានបរិស្ថាន ។
- សហការជាមួយខ័ណ្ឌរដ្ឋបាលជលផល នៅក្នុងខេត្តព្រះសីហនុ ដើម្បីការពារនូវធនធានជលផលជុំវិញតំបន់កោះពស់ ។
- ក្រុមហ៊ុនកោះពស់ត្រូវតែគោរពតាមកិច្ចសន្យាជាមួយរាជរដ្ឋាភិបាលកម្ពុជា និងធ្វើការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរក្នុងតំបន់ និងមន្ទីរជំនាញផ្សេងៗទៀត ។

## ៤.៣ សេចក្តីសន្និដ្ឋាន និងអនុសាសន៍

តាមលទ្ធផលនៃកិច្ចពិគ្រោះយោបល់ជាសាធារណៈ និងកិច្ចប្រជុំជាមួយអ្នកដែលពាក់ព័ន្ធ គេអាចសន្និដ្ឋានថា ប្រជាជនមូលដ្ឋាន មន្ទីរជំនាញនៅក្នុងក្រុងព្រះសីហនុ វិស័យឯកជន អាជ្ញាធរកំពង់ផែ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ទាំងអស់បានទទួលស្វាគមន៍គាំទ្រគំរោងមរកត។ ពួកគេទាំងអស់បានយល់ពីគំរោងមរកត នឹងផ្តល់ផលប្រយោជន៍ច្រើនទៅដល់ការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងខេត្តទាំងមូល និងផ្តល់ឱកាសការងារច្រើនទៅដល់ប្រជាជនមូលដ្ឋាន និងមានការរីកចំរើនសេដ្ឋកិច្ចជាតិ។

ទោះជាយ៉ាងណាក៏ដោយ គំរោងនឹងអាចផ្តល់នូវបញ្ហាខ្លះៗទៅដល់កំពង់ផែកំពង់សោម ការរំខាន ដល់នាវាខ្នាតធំ និងអាចមានខ្យល់បោកបក់មកលើតំបន់កំពង់ផែ ហើយអាចកាត់បន្ថយប្រសិទ្ធភាពសេវាកម្មរបស់កំពង់ផែ។ ក្រៅពីនេះ សកម្មភាពសាងសង់របស់គំរោងអាចមានផលប៉ះពាល់ទៅដល់ប្រព័ន្ធអេកូឡូស៊ីឆ្នេរ និងសកម្មភាពទេសចរណ៍ដែលស្ថិតនៅក្បែរតំបន់គំរោង។

អនុសាសន៍ ឬក៏យោបល់មួយចំនួនដែលត្រូវបានគេលើកឡើងពីការពិគ្រោះយោបល់ និងកិច្ចប្រជុំជាមួយនឹងប្រជាជន និងអ្នកដែលពាក់ព័ន្ធនឹងគំរោងមានដូចតទៅ:

- លើកទឹកចិត្ត/ជំរុញការអនុវត្ត ដោយហេតុថាតំរូវការអភិវឌ្ឍន៍ និងធ្វើឱ្យប្រជាជនមានទំនុកចិត្តទៅលើគំរោងនេះ។
- ការសាងសង់ត្រូវតែអនុលោមទៅតាមគោលការណ៍ និងបទដ្ឋានរបស់ក្រសួងនានា និងអង្គភាពជំនាញនៃរាជរដ្ឋាភិបាលកម្ពុជា។
- ផ្តល់ព័ត៌មានគំរោង និងផលប្រយោជន៍របស់គំរោងទៅដល់ប្រជាជន។
- សហប្រតិបត្តិការល្អជាមួយនឹងស្ថាប័នជំនាញនៅក្នុងការងារសាងសង់ដើម្បីឱ្យស្របទៅតាមគោលការណ៍/បទបញ្ជា និងច្បាប់របស់ប្រទេសកម្ពុជា។
- ធានាក្នុងការគ្រប់គ្រងកាកសំណល់ (រឹង និងរាវ) ពីសកម្មភាពគំរោង។
- ត្រូវផ្តល់ព័ត៌មានពីសកម្មភាពការងារប្រចាំសប្តាហ៍ ឬក៏ប្រចាំខែទៅដល់មន្ទីរជំនាញដែលពាក់ព័ន្ធ។
- ត្រូវអនុញ្ញាតឱ្យអ្នកប្រើប្រាស់ស្ពានដោយឥតបង់ថ្លៃ (ឆ្លងស្ពានដោយមិនបាច់បង់ប្រាក់)។
- ស្ថាបនាការិយាល័យទេសចរណ៍នៅខាងមុខស្ពាន (ដូចជាស្ពានសេកុង នៅក្នុងខេត្តស្ទឹងត្រែង)។
- ប្រសិនបើមានលទ្ធភាពក្រុមហ៊ុនអាចរៀបចំស្ថានីយ៍ប៉ូលីសទេសចរណ៍នៅចំណុចចាប់ផ្តើមនៃស្ពាន។
- ត្រូវអនុញ្ញាតឱ្យវិស្វករពី ២នាក់ ទៅ ៣នាក់ របស់មន្ទីរសាធារណការ និងដឹកជញ្ជូនចូលធ្វើការនៅក្នុងអំឡុងពេលសាងសង់ ដើម្បីបណ្តុះបណ្តាលសមត្ថភាពដល់អ្នកបច្ចេកទេសកម្ពុជា។

# ៥. ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងវិធានការណ៍បន្ធូរបន្ថយ

ក្រុមសិក្សាបរិស្ថានបានធ្វើការអង្កេតនៅទីតាំងជាក់ស្តែង និងត្រួតពិនិត្យមើលសក្តានុពលនៃហេតុប៉ះពាល់ទាំងវិជ្ជមាន និងអវិជ្ជមាន ហើយរៀបចំនូវវិធានការកាត់បន្ថយចំពោះហេតុប៉ះពាល់ជាអវិជ្ជមាន នីមួយៗ។

ដើម្បីត្រួតពិនិត្យពីសកក្តានុពលនៃហេតុប៉ះពាល់បរិស្ថានសំខាន់ ក្រុមសិក្សាបានប្រើប្រាស់បញ្ជីពិនិត្យវាយតំលៃបរិស្ថាន។ ផ្អែកតាមលទ្ធផលនៃការអង្កេតនៅទីតាំងជាក់ស្តែងទៅលើបរិស្ថាន និងសង្គមនៅក្នុងតំបន់គំរោងបង្ហាញថា សក្តានុពលនៃហេតុប៉ះពាល់បរិស្ថានដែលរំពឹងទុកថានឹងកើតឡើងដោយសកម្មភាពគំរោង មុនពេលសាងសង់ ពេលសាងសង់ និងដំណាក់កាលប្រតិបត្តិគំរោងត្រូវបានសង្ខេប ដោយភ្ជាប់នូវវិធានការកាត់ បន្ថយសំរាប់ហេតុប៉ះពាល់អវិជ្ជមាននីមួយៗដូចតទៅៈ-

## ៥.១ ផលប៉ះពាល់អវិជ្ជមាន

- **ដំណាក់កាលមុនពេលសាងសង់**

**<u>១-ទីតាំងគំរោង និងការរចនាប្លង់:</u>**

ការរៀបចំខ្សែបន្ទាត់ស្ពានកាត់តាមឃ្លងធម្មជាតិនៅក្នុងតំបន់កោះពស់ ដែលជាកន្លែងផ្លូវនាវាចរណ៍សំរាប់កប៉ាល់ចេញចូលទៅផែកំពង់សោម។ ដូចនេះស្ពាននឹងជាឧបសគ្គដល់ការធ្វើនាវាចរណ៍ខ្នាតធំ យោងតាមប្លង់កំពស់ស្ពានមានត្រឹមតែ ៣២.៥ម ពីផ្ទៃទឹកខ្ពស់បំផុតក្នុងតំបន់នេះ។ ផ្អែកតាមទំហំនាវាដែលបានឆ្លងកាត់ឃ្លងនេះ ក្រសួងសាធារណការ និងដឹកជញ្ជូន បានស្នើទៅក្រុមហ៊ុនកោះពស់ដើម្បីរកលទ្ធភាព សាងសង់ស្ពានកោះពស់នេះដែលមានកំពស់ ៣៧.៥ម ពីផ្ទៃទឹកសមុទ្រខ្ពស់បំផុតនៅទីនេះ។

សមាសធាតុជំនួយផ្សេងៗទៀតរបស់គំរោងដូចជាម៉ាស៊ីនលាយស៊ីម៉ង់ត៍ កន្លែងស្តុកទុកស៊ីម៉ង់ត៍ និងជំរុំកម្មករជាដើម ដែលរៀបចំដាក់នៅលើទីលានដីគោកនៅតាមមាត់សមុទ្រជិតសំណង់ស្ពាន និងឆ្នេរហាវ៉ៃនឹងធ្វើឱ្យមានការមិនសប្បាយចិត្តដល់អ្នកជិតខាង និងអ្នកទេសចរណ៍នៅឆ្នេរលំហែកាយ និងឆ្នេរហាវ៉ៃ ទោះបីជាសំណង់នោះស្ថិតនៅក្នុងដីជួលរបស់គំរោងក៏ដោយ។

*<u>វិធានការកាត់បន្ថយ</u>*

*ការជ្រើសរើសទីតាំងគំរោង និងកំពស់ស្ពានកោះពស់ត្រូវបានដោះស្រាយដោយអន្តរក្រសួងដែលដឹកនាំដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដោយមានការឯកភាពពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។ នៅក្នុងលិខិតលេខ ៧៧៨/០៨ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានបញ្ជាក់ថា ស្ពានអាចសាងសង់នៅកំពស់ពី ២៨ម ទៅ ៣២ម ពីផ្ទៃទឹកខ្ពស់បំផុត។ ជាងនេះទៀត ក្នុងប្រការ៣នៃ "កិច្ចសន្យាបន្ថែមស្តីពី ការកែសំរួលខ្លឹមសារក្នុងកិច្ចសន្យាជួលកោះពស់ និងដីឆ្នេរកោះពស់(ឆ្នេរហាវ៉ៃ) ក្រុងព្រះសីហនុ ពាក់ព័ន្ធនឹងការប្តូរទីតាំងសាងសង់តល់ស្ពាន (ផ្នែកដីគោក)*



Draft

*តភ្ជាប់ពីផ្ទែកដីគោកទៅកោះពស់'' (ឧបសម្ព័ន្ធទី២យ) បានថែងថា ភាគី “ ខ ” (ក្រុមហ៊ុនកោះពស់ (ខេមបូឌា) អុិនវេសមេនគ្រុប អេលធីឌី) ត្រូវអនុវត្តតាមគោលការណ៏ បច្ចេកទេស ដូចខាងក្រោមៈ-*

- ***កំពស់ស្ពានៈ*** *ត្រង់ចំនុចគន្លងនាវាចរ ត្រូវមានកំពស់យ៉ាងទាប ៣២ម៉ែត្រ គិតចាប់ពីផ្ទៃទឹកពេលទឹកសមុទ្រជោរខ្ពស់បំផុត ។*
- ***គំលាតសរសរស្ពានៈ*** *នៅត្រង់តំបន់គន្លងនាវាចរ ការសាងសង់សរសរស្ពាន ត្រូវមានគំលាតពីគ្នាយ៉ាងតិច ១៥០ ម៉ែត្រ ដើម្បីសំរួលដល់ចរាចរនាវា ។*
- ***សំភារះតាំងភ្ជាប់ និងស្លាកសញ្ញាចរាចរៈ*** *ត្រូវមានគំនូសចរាចរ-បំពាក់ភ្លើងអគ្គិសនីតាមបណ្តោយស្ពានរួមទាំងខាងលើ និងខាងក្រោមស្ពានផងដែរ-បំពាក់បង្កាន់ដៃស្ពាន-បំពាក់ស្លាកសញ្ញាចរាចរផ្សេង១ទៀតតាមលក្ខណៈបច្ចេកទេសកំណត់ ។*
- ***លក្ខណៈបច្ចេកទេសសាងសង់ស្ពានៈ*** *ត្រូវគោរពតាមការណែនាំរបស់ភាគី “ ក ” និងក្រសួង-ស្ថាប័នមានសម្ថកិច្ចពាក់ព័ន្ធ ក្នុងនោះរួមទាំងសុវត្ថិភាពការងារក្នុងពេលសាងសង់ផងដែរ ។*

*គណៈកម្មការត្រួតពិនិត្យបទដ្ឋានបច្ចេកទេសសាងសង់ស្ពានកោះពស់ បានបង្កើតតាំងពី ខែមករា ឆ្នាំ ២០០៨ ដោយក្រសួងសាធារណការ និងដឹកជញ្ជូន ដែលមានភារកិច្ចដើម្បី (១) អធិការកិច្ច និងកែតំរូវទៅតាមបទដ្ឋានបច្ចេទេស និងសំណង់វិស្វកម្មស្ពាន (២)រៀបចំកិច្ចប្រជុំចាំបាច់ និងពិភាក្សាជាមួយក្រុមហ៊ុនវិនិយោគ និងភាគីពាក់ព័ន្ធផ្សេងទៀត ។*

*ក្រុមហ៊ុនកោះពស់នឹងគោរពតាមប្លង់វិស្វកម្មទាំងអស់ដែលបានយល់ព្រមដោយអន្តរក្រសួង ព្រមទាំងធ្វើកិច្ច សហការល្អជាមួយគណៈកម្មការត្រួតពិនិត្យបទដ្ឋានបច្ចេកទេសសាងសង់ស្ពានកោះពស់ ។*

*ពិភាក្សាជាមួយអ្នកជិតខាងនៃទីកន្លែងគំរោងដោយសន្តិវិធី និងសហប្រតិបត្តិការល្អជាមួយអាជ្ញាធរមូលដ្ឋាន អ្នកដឹកនាំសហគមន៏ ឬមេភូមិនៅពេលរៀបចំតួរប្លង់ និងការរៀបចំដាក់សមាសធាតុទាំងអស់របស់គំរោង ជាពិសេស សមាសភាពគំរោងនៅការដ្ឋានឆ្នេរហាវ៉ៃ និងស្ពានកោះពស់ ។*

Draft

- **ដំណាក់កាលសាងសង់**

## ១-<u>ផ្លូវនាវាចរណ៏ និង កំពង់ផែកំពង់សោម</u>

គំរោងនឹងរំខានទាំងស្រុងដល់ផ្លូវនាវាចរណ៏កាត់តាមឃ្លងធម្មជាតិនៅតំបន់កោះពស់ ចំពោះនាវាគ្រប់ប្រភេទចេញចូលផែកំពង់សោមអំឡុងពេលសាងសង់ ។ នៅក្នុងពេលសាងសង់ស្ពាន នាវាទាំងអស់រាប់បញ្ចូលទាំងទូកនេសាទផង នឹងមិនអនុញ្ញាតិអោយឆ្លងកាត់ឃ្លងធម្មជាតិនៅពីក្រោមទីតាំងស្ពានទេ។ មានបញ្ហាខ្លះ១ចំពោះ ប្រតិបត្តិការកំពង់ផែ ដោយសារនៅពេលនេះមិនទាន់មានការសាងសង់ផ្លូវឃ្លងវាងថ្មីនៅឡើយ ។ ដូចនេះនាំឱ្យថយចុះកិច្ចដំណើរការរបស់កំពង់ផែ ឬប៉ះពាល់ដល់សកម្មភាពដឹកជញ្ជូនតាមកប៉ាល់របស់ផែកំពង់សោម ។

*<u>វិធានការកាត់បន្ថយ</u>*

- *ក្រុមហ៊ុននឹងធ្វើសហប្រតិបត្តិការល្អជាមួយអាជ្ញាធរកំពង់ផែកំពង់សោម និងព្យាយាមរកវិធីល្អបំផុតសំរាប់ការស្វែងរកផ្លូវបណ្តោះអាសន្នសំរាប់សកម្មភាពនាវាចរណ៍ ក្នុងដំណាក់កាលសាងសង់ ។*
- *ជូនដំណឹងឱ្យបានគ្រប់គ្រាន់ដល់អ្នកនេសាទ ភ្នាក់ងារទេសចរណ៍ និងប្រជាជនមូលដ្ឋានឱ្យប្រើប្រាស់ផ្លូវនាវាចរណ៍ផ្សេងទៀតសំរាប់បើកបរទូករបស់គេ នៅឆ្ងាយពីការដ្ឋានសាងសង់ស្ពានដើម្បីជៀសវាងគ្រោះថ្នាក់ដែលអាចកើតមានឡើងដោយថាហេតុ ។*
- *មានផ្តល់ស្លាកសញ្ញាសុវត្ថិភាពនៅជុំវិញការដ្ឋានស្ពាន និងមានបណ្តែតពោងបង្ហាញទិសដៅសំរាប់ការធ្វើនាវាចរណ៍វាងការដ្ឋានសាងសង់ទៀតផង ។*
- *សហប្រតិបត្តិការល្អជាមួយអជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធនៅក្នុងក្រុងព្រះសីហនុ ដើម្បីរៀបចំគ្រប់គ្រង និងដោះស្រាយចំពោះបញ្ហាក្នុងការដ្ឋានសាងសង់ ។*

## <u>២-ការហូរច្រោះដី:</u>

ការងារដី និងកាប់ឆ្ការដំណាំនៅឯទីតាំងសំណង់ស្ពានកោះពស់ ការកសាងផ្លូវ និងការសាងសង់អាគារក្នុងការដ្ឋានសំណង់កោះពស់នឹងអាចបណ្តាលឱ្យមានការហូរច្រោះដីព្រោះ សណ្ឋានដីនៅលើកោះពស់មានលក្ខណៈចោទបន្តិច និងលក្ខណៈដីនៅតំបន់គំរោងដែលភាគច្រើនជាដីល្បាយខ្សាច់ ហើយម្យ៉ាងទៀតនៅទីនេះមានកំណកបរិយាកាសខ្ពស់ ព្រោះជាតំបន់ឆ្នេរ ។

*<u>វិធានការកាត់បន្ថយ</u>*

- *ការសំអាតរុក្ខជាតិក្នុងការដ្ឋានសាងសង់នានារបស់គំរោងមរកត នឹងត្រូវកំណត់ទំហំជាអប្បបរមាសំរាប់តែការសាងសង់ ។*
- *ការឈូសឆាយដីនៅក្នុងការដ្ឋានសាងសង់នឹងត្រូវធ្វើតែនៅរដូវប្រាំង ឬគ្មានភ្លៀងធ្លាក់ ដើម្បីកាត់បន្ថយសំណឹកដីពីកន្លែងសាងសង់ក្នុងកំឡុងពេលសាងសង់ ។*
- *វិធានការ/ការទប់ស្កាត់សំណឹកដីសមស្រប នឹងត្រូវអនុវត្ត ដូចជាការដាំដុះរុក្ខជាតិឡើងវិញភ្លាមៗបន្ទាប់ពីបកស្រទាប់ដីលើ ជីកធ្វើជាថ្នាក់ៗដើម្បីបន្ថយជំរាលចោត ឬតម្រៀបថ្មនៅកន្លែងដែលមានដីងាយទទួលរងសំណឹក ។*

## <u>៣-ហេតុប៉ះពាល់លើភាវរសក្នុងទឹក/មច្ឆា</u>

នៅដំណាក់កាលសាងសង់ គំរោងអាចប៉ះពាល់ដល់ជីវិតសត្វក្នុងទឹកដូចជា មឹក បង្គា ត្រី ត្រីតុកែ និងផ្កាថ្មដែលរស់នៅក្នុងតំបន់កោះពស់ ។ ហេតុប៉ះពាល់ដល់ធនធានទាំងនោះបណ្តាលពីការប្រែប្រួលគុណភាពទឹក (ទឹកមានកករ/ភាពល្អក់ខ្ពស់ កាកសំណល់កំពប់ចូលទៅក្នុងទឹក សំលេង និង រំញ័រចេញពីសកម្មភាពសាងសង់) ។

Draft

កករល្អក់ទឹក នឹងបណ្តាលអោយមានកំទេចកំណខ្ពស់នៅក្នុងបាតសមុទ្រ ដែលជាជំរករបស់ស្មៅសមុទ្រ ផ្កាថ្ម និងពពួកត្រីតុកែ ។ ការកំពប់កាកសំណល់ចូលក្នុងទឹក ជាពិសេស ប្រេងឥន្ធនៈ និងប្រេងរំអិល និងកាកសំណល់គ្រោះថ្នាក់ចេញពីសំភារៈសំណង់ នឹងបង្កហេតុប៉ះពាល់ខ្លាំងចំពោះជីវិតសត្វក្នុងទឹក និងត្រី ។

ជួនកាលការនេសាទខុសច្បាប់ (ការបំផ្ទុះ ឬការប្រើថ្នាំបំពុល) ពីសំណាក់កម្មករសំណង់ក៏បណ្តាលអោយមានហេតុប៉ះពាល់ ឬបំផ្លាញភាពរស់ក្នុងទឹក និងធនធានមច្ឆានៅក្នុងកំពង់ផងដែរ ។

*<u>វិធានការកាត់បន្ថយ</u>*

- *ការទប់ស្កាត់កករដី និងកំទេចកំណឱ្យបានល្អគឺជាតំរូវការចាំបាច់នៅគ្រប់កន្លែងនៃការដ្ឋានសាងសង់នៅក្នុងទឹក និងនៅឆ្នេរសមុទ្រ/មាត់ទឹក ។ ជាឧទាហរណ៍ គេអាចដាក់ក្រណាត់ស្ទាក់កករដីនៅជុំវិញកន្លែងសាងសង់នៅក្នុងទឹក ហើយសាងសង់ស្រះរងកករនៅកន្លែងសាងសង់នៅឆ្នេរសមុទ្រ ឬតាមមាត់ទឹក ។*
- *គ្រប់គ្រងសំណល់ប្រេងម៉ាស៊ីន ឬប្រេងរំអិលនានាឱ្យបានត្រឹមត្រូវ ដោយប្រមូលទុកដាក់ក្នុងធុង និងប្រើប្រាស់ឡើងវិញ ឬលក់ឱ្យអ្នកយកទៅប្រើក្នុងបំណងផ្សេងៗ ។ ថែទាំ និងជួសជុលគ្រឿង ចក្រ និងយានយន្តរបស់កំពង់មិនឱ្យលេចកំពប់ប្រេង/ខ្លាញ់លើដី ឬក្នុងទឹក ។*
- *អប់រំដល់កម្មករមិនឱ្យចោលកាកសំណល់ចូលទៅក្នុងប្រភពទឹក ហើយផ្តល់មធ្យោបាយគ្រប់គ្រាន់ដើម្បីគ្រប់គ្រងកាកសំណល់ រួមបញ្ចូលទាំងសាងសង់បង្គន់អនាម័យនៅក្នុងទឹកន្លែងសាងសង់ និងជំរុំស្នាក់នៅ ។ ក្រុមហ៊ុនធានាថា រាល់កាកសំណល់ទាំងអស់ដែលបានបង្កើតពីមនុស្ស និងពីសកម្មភាពសាងសង់នឹងត្រូវបានប្រមូល និងយកទៅបោះចោលត្រឹមត្រូវស្របទៅតាមអនុក្រឹត្យនៃការគ្រប់គ្រងសំណល់រឹង របស់ក្រសួងបរិស្ថាននៃរាជរដ្ឋាភិបាលកម្ពុជា ។*
- *ហាមឃាត់ដាច់ខាតចំពោះកម្មករសំណង់ មិនឱ្យធ្វើនេសាទខុសច្បាប់ ហើយក្រុមហ៊ុនធ្វើកិច្ចសហការជាមួយខ័ណ្ឌរដ្ឋបាលជលផលខេត្តព្រះសីហនុ ដើម្បីធ្វើអធិការកិច្ច និងទប់ស្កាត់សកម្មភាពនេសាទខុសច្បាប់នៅក្នុងតំបន់កំពង់ ។*

**<u>៤-កាកសំណល់</u>**

សំណល់រឹងដូចជា កាកសំណល់នៃសំភារៈសាងសង់ សំណល់ផ្ទះបាយ និងសំណល់ចេញពីមនុស្សអាចកើតមានឡើងនៅការដ្ឋានសាងសង់ និងជំរុំស្នាក់នៅរបស់បុគ្គលិក/កម្មករកំពង់។ កាកសំណល់ពីការដ្ឋានសាងសង់ ដូចជា កំទេចកំទីនៃ សំភារៈសំណង់ (ក្រដាស ជ័រ ឈើ ដែក អាចម៍ដី ។ល។) និងសំណល់ប្រេងឥន្ធនៈ ប្រេងរំអិល ឬខ្លាញ់ពីគ្រឿងចក្រសាងសង់ ជាតិពុលនានាពីសំភារៈសាងសង់។ សំណល់ចេញពីបុគ្គលិកកម្មករ និងផ្ទះបាយកំពង់ ដូចជា សំណល់បន្លែ ឆ្អឹងត្រី ឆ្អឹងសត្វ ថង់ប្លាស្ទិក/ស្បោង សំណល់អាហារ លាមក និងទឹកនោម ។

ការគ្រប់គ្រងកាកសំណល់ក្នុងការដ្ឋានសាងសង់ និងក្នុងជំរុំស្នាក់នៅរបស់បុគ្គលិក/កម្មករមិនបានល្អ នឹងបង្កឱ្យមានបញ្ហាជាច្រើនដល់ធនធានបរិស្ថាន និងសង្គមក្នុងតំបន់គំរោង។ បញ្ហាទីមួយគឺ ធ្វើឱ្យខូចសោភ័ណ្ឌភាព បញ្ហាទីពីរ គឺបំពុលដល់គុណភាពដី គុណភាពខ្យល់ និងគុណភាពទឹក បញ្ហាទីបីគឺបង្កើតជំរក និងសត្វចង្រៃចំលងរោគ ដូចជា ម៉ូស រុយ ហើយបញ្ហាចុងក្រោយគឺ ប៉ះពាល់ដល់សុខភាពសត្វក្នុងទឹក សត្វពាហនៈនានា និងសុខភាពមនុស្ស នៅក្នុងតំបន់គំរោង និងតំបន់ជិតខាង។

*<u>វិធានការបន្ធូរបន្ថយ</u>*

- *ក្រុមហ៊ុននឹងអប់រំកម្មករមិនឱ្យបោះចោលកាកសំណល់ទៅក្នុងខ្សែទឹក និងផ្តល់ឱ្យនូវសេវាកម្មគ្រប់គ្រងសំរាមរួមទាំងបង្គន់អនាម័យក្នុងទីតាំងការដ្ឋានសាងសង់ និងក្នុងជំរុំបុគ្គលិក/កម្មករ។ ក្រុមហ៊ុនកោះពស់នឹងធ្វើកិច្ចសន្យាជាមួយក្រុមហ៊ុនប្រមូលសំរាមនៅក្នុងក្រុងព្រះសីហនុ ដើម្បីប្រមូល និងដឹកយកកាកសំណល់ទាំងអស់ដែលចេញពីមនុស្ស និងពីសកម្មភាពសាងសង់ ទៅបោះចោលដោយផ្អែកទៅតាមបទបញ្ជា ឬក៏គោលការណ៍ណែនាំអំពីការគ្រប់គ្រងកាកសំណល់រឹងរបស់ប្រទេសកម្ពុជា។ ជាក់ស្តែង ក្រុមហ៊ុនកោះពស់មានកិច្ចសន្យាជាមួយក្រុមហ៊ុន CINTRI សាខាក្រុងព្រះសីហនុ ដើម្បីប្រមូលសំរាមការិយាល័យ និងសំរាមផ្ទះបាយយកទៅបោះចោល សូមមើលឧបសម្ព័ន្ធទី៥។*
- *ក្រុមហ៊ុននឹងសាងសង់ស្រះរងកករ ដែលមានតួនាទីសំអាតបឋមនៃទឹកដែលប្រើប្រាស់ចេញពីការដ្ឋានសាងសង់ និងជំរុំស្នាក់នៅរបស់បុគ្គលិក/កម្មករ។ សំភារៈសំលាប់មេរោគ ដូចជាម្សៅកំបោររស់ និងក្ល័រនឹងត្រូវបានប្រើដើម្បីសំអាតទឹកក្នុងស្រះរងកករ ក្នុងករណីបើចាំបាច់។*
- *គ្រប់គ្រងសំណល់សំភារៈសំណង់ឱ្យបានត្រឹមត្រូវ ដូចជា ឈើ ដែក ក្រដាស និងស្បោងប្លាស្ទិក ព្រមទាំងសំណល់ប្រេង និងប្រេងរំអិលចេញពីគ្រឿងចក្រសាងសង់ ដោយប្រមូលទុកក្នុងធុងដើម្បីប្រើប្រាស់ឡើងវិញ ឬលក់ឱ្យអ្នកប្រើប្រាស់ផ្សេងទៀត។*

- **ដំណាក់កាលប្រតិបត្តិគំរោង**

**<u>១-សិទ្ធិប្រើប្រាស់ទឹក និងសិទ្ធិទូទៅ</u>**

ថ្វីត្បិតតំបន់កោះពស់មិនមែនជាតំបន់នេសាទសំខាន់នៃក្រុងព្រះសីហនុ ប៉ុន្តែមានគ្រួសារអ្នកនេសាទប្រហែល ៥០គ្រួសារ ដែលតែងតែធ្វើនេសាទនៅទីនេះជារៀងរាល់ឆ្នាំ ជាពិសេសនៅរដូវប្រាំង (រយៈពេល២ខែក្នុងមួយឆ្នាំ) ហើយមានពីរបីគ្រួសារធ្វើនេសាទទីនេះពេញមួយឆ្នាំ។ គំរោងនឹងមានហេតុប៉ះពាល់ដល់សកម្មភាពនេសាទរបស់អ្នកនេសាទមួយចំនួនដែលធ្វើនេសាទនៅក្បែរតំបន់កោះពស់ និងនៅខាងមុខឆ្នេរហាវ៉ៃ បើសិនគំរោងនឹងហាមឃាត់សកម្មភាពនេសាទបែបគ្រួសារនៅទីនេះ។ ព្រោះថា នៅពេលគំរោងដាក់ឱ្យដំណើរការនោះ សកម្មភាពនេសាទ

Draft

បែបគ្រួសារប្រមាណជា៥០% នឹងត្រូវបាត់បង់ដោយសារ ការកំណត់ដែននេសាទនៅតំបន់កោះពស់ ហើយនឹងប៉ះពាល់ដល់ចំណូលអ្នកនេសាទ ឬគ្រួសារនេសាទប្រមាណជា ៥៣.០០០ ដុល្លាសហរដ្ឋអាមេរិកក្នុងមួយឆ្នាំ ។

*<u>វិធានការកាត់បន្ថយ</u>*

- *ក្រុមហ៊ុនកោះពស់នឹងអនុញ្ញាតឱ្យអ្នកនេសាទធ្វើសកម្មភាពនេសាទនៅតំបន់កោះពស់ក្នុងចំងាយកំណត់ច្បាស់លាស់ពីមាត់ឆ្នេរនៃកោះ ដោយមានដាក់បណ្តែតពោងសញ្ញាដែនកំណត់ជុំវិញកោះ ។*
- *ក្រុមហ៊ុននឹងអនុញ្ញាតឱ្យអ្នកនេសាទធ្វើសកម្មភាពនេសាទជុំវិញកោះពស់ក្នុងចំងាយ ១០០ម៉ែត្រពីមាត់ទឹក ដើម្បីថែរក្សាភាពស្ងប់ស្ងាត់ និងសុវត្ថិភាពដល់ប្រជាជន និងភ្ញៀវដែលរស់នៅលើកោះ ។*
- *ក្រុមហ៊ុននឹងផ្តល់អាទិភាពជ្រើសរើសគ្រួសារអ្នកនេសាទដែលនឹងរងផលប៉ះពាល់ឱ្យចូលធ្វើការជាបុគ្គលិក/កម្មកររបស់គំរោងទេ អំឡុងពេលប្រតិបត្តិគំរោង ។*

## <u>២-ហេតុប៉ះពាល់ទៅលើ ភាវរសក្នុងទឹក/មច្ឆា</u>

ហេតុប៉ះពាល់លើវារីសត្វ/ត្រី អាចនឹងកើតមានឡើង ដោយសារការបង្ហូរទឹកក្រខ្វក់ដែលគ្មានការសំអាតចូលក្នុងប្រភពទឹក ការពង្រាយសំរាម/សំណល់រឹងនៅលើឆ្នេរ ឬតាមមាត់ទឹក ។ គំរោងនឹងមានហេតុប៉ះពាល់តិចតួចទៅមធ្យមលើវារីសត្វ/វារីរុក្ខជាតិ ជាមួយនឹងការបណ្តុំជាតិពុលជាបន្តបន្ទាប់ហូរចូលទៅក្នុងទឹក ។

សកម្មភាពនេសាទច្រើន និងការប្រមូលយកវារីសត្វនៅតាមមាត់ច្រាំងនៃតំបន់កោះពស់អាចនឹងកើតមានឡើង ។ ដោយសារភាពងាយស្រួលក្នុងការចេញចូលបណ្តាលមកពីកិច្ចដំណើរការស្ពានអាចទាក់ទាញដល់អ្នកនេសាទ ឬ ភ្ញៀវទេសចរណ៍ចូលមក និងធ្វើនេសាទនៅតាមក្បែរច្រាំងកោះពស់ ។

*<u>វិធានការកាត់បន្ថយ</u>*

- *គំរោងមរកតមានផែនការទប់ស្កាត់ និងធ្វើឱ្យប្រសើរឡើងនូវធនធានធម្មជាតិសំរាប់ការអភិវឌ្ឍន៍ផ្នែកទេសចរណ៍ ដូចនេះសកម្មភាពនេសាទ និងការប្រមូលវារីសត្វនឹងត្រូវមានកំណត់ ។*
- *ក្រុមហ៊ុននឹងធ្វើសហប្រតិបត្តិការល្អជាមួយខ័ណ្ឌរដ្ឋបាលជលផលខេត្តព្រះសីហនុ និងអនុញ្ញាតឱ្យអ្នកនេសាទធ្វើសកម្មភាពនេសាទនៅតំបន់កោះពស់ក្នុងចំងាយដែនកំណត់ពីមាត់ច្រាំង (យ៉ាងតិច ១០០ ម៉ែត្រ ពីច្រាំងកោះពស់)*
- *គ្រប់គ្រងឱ្យបានល្អចំពោះកាកសំណល់ដែលកើតចេញពីការប្រតិបត្តិគំរោង ។ ត្រួតពិនិត្យយ៉ាងខ្ជាប់ខ្ជួននូវអាងធ្វើប្រព្រឹត្តិកម្មទឹកស្អុយឱ្យមានដំណើរការល្អ ហើយតំលៃនៃប៉ារ៉ាម៉ែត្របង្ហូរចេញគោរពតាមបទដ្ឋាននៃការបង្ហូរចូលតំបន់ទឹកធម្មជាតិដែលកំណត់ដោយក្រសួងបរិស្ថាន ។*
- *ក្រុមហ៊ុននឹងធ្វើសហប្រតិបត្តិការល្អជាមួយខ័ណ្ឌរដ្ឋបាលជលផលខេត្តព្រះសីហនុ ដើម្បីត្រួតពិនិត្យតាមដានវារីសត្វ/ត្រី និងវារីរុក្ខជាតិក្នុងតំបន់កោះពស់ទាំងមូលអំឡុងពេលដំណើរការគំរោង ។*

Draft

*នឹងមានផែនការធ្វើអង្កេតលើត្រី និងផ្កាថ្មនៅជុំវិញកោះពស់ (១០០ម ពីមាត់ច្រាំង) ជារៀងរាល់ពីរឆ្នាំម្តងពេញរយៈពេលប្រតិបត្តិការគំរោង ដើម្បីពិនិត្យមើលធនធានធម្មជាតិនេះ និងរកដំណោះស្រាយធ្វើយ៉ាងណារក្សានិរន្តភាពវាឱ្យបាន។*

## ៥.២ បន្ទុំនៃផលប៉ះពាល់

បណ្តុំនៃផលប៉ះពាល់នឹងត្រូវបានកើតមានឡើងនៅក្នុងដំណាក់ការសាងសង់ និងក្នុងពេលប្រតិបត្តិការគំរោងនៃបន្ទុំសកម្មភាពអភិវឌ្ឍន៍ដទៃទៀតនៅក្នុងគំរោង ដូចជាមណ្ឌលលំហែកាយ និងមណ្ឌលពាណិជ្ជកម្ម Emario នៅជិតតំបន់កោះពស់ (ដោយក្រុមហ៊ុនជប៉ុន) សកម្មភាពកំពង់ផែក្រុងព្រះសីហនុ និងសកម្មភាពអភិវឌ្ឍន៍ទីក្រុងនៅក្នុងទីកដីសង្កាត់លេខ៣ និងក្នុងក្រុងព្រះសីហនុទាំងមូល។

បណ្តុំនៃផលប៉ះពាល់នៅក្នុងតំបន់គំរោងរួមមាន **ការបាត់បង់ឆ្នេរសាធារណៈ ការប្រើប្រាស់ទឹកស្អាតក្រុង ចរាចរណ៍ ការបំពុលខ្យល់ ការបំពុលទឹក និងកាកសំណល់**ពី ការសាងសង់ និងសកម្មភាពប្រតិបត្តិការនៃគំរោងទាំងនោះ។

## ៥.៣ ផលប៉ះពាល់បរិស្ថានជាវិជ្ជមាន

**ហេដ្ឋារចនាសម្ព័ន្ធៈ** គំរោងមរកត នឹងបន្ថែមហេដ្ឋារចនាសម្ព័ន្ធច្រើនថែមទៀតក្នុងក្រុងព្រះសីហនុ ដូចជាស្ពានបេតុងថ្មីមួយដោយមានរបវែងសរុប៩០០ម៉ែត្រ និងមានផ្លូវរាប់រយម៉ែត្រទាំងសងខាងស្ពានដែលអាចភ្ជាប់ដីគោក និងដីកោះពស់ សំណង់រូបវ័ន្តបំរើឱ្យទេសចរណ៍ ពាណិជ្ជកម្ម សេវាកម្មសាធារណៈ តំបន់លំនៅដ្ឋាន និងមធ្យោបាយដឹកជញ្ជូន។

**ផលប្រយោជន៍នៃបរិស្ថានៈ** គំរោងមរកត នឹងជួយការពារលើធនធានសត្វរស់នៅក្នុងទឹក/ត្រីក្នុងតំបន់កោះពស់ និងអាចការពារការនេសាទ និងការប្រមូលផ្កាថ្មខុសច្បាប់ ដើម្បីធ្វើឱ្យប្រសើរឡើងនៃវារីសត្វ និងរុក្ខជាតិនៅក្នុងតំបន់កោះពស់ទាំងមូល។

**ផ្តល់ការងារៈ** គំរោង នឹងផ្តល់ការងារយ៉ាងច្រើនដល់ប្រជាជនមូលដ្ឋានក្នុងខេត្តព្រះសីហនុ ជាកម្មករ និងបុគ្គលិកចំនួន៩៩០នាក់អំឡុងពេលសាងសង់ និង១៤៧០នាក់ជាកម្មករ និងបុគ្គលិកក្នុងអំឡុងពេលប្រតិបត្តិគំរោង។ អ្នកបច្ចេកទេស និងវិស្វករកម្ពុជាមានឱកាសធ្វើការសំរាប់គំរោងនេះផងដែរ។

**ទេសចរណ៍ៈ** គំរោងមរតកនេះ នឹងផ្តល់ឱ្យនូវភាពសម្បូណ៌បែបខាងហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់ឆ្នេរ ដែលអាចបំរើទៅដល់តំបន់ដែលមានសក្តានុពលមួយសំរាប់ការអភិវឌ្ឍទេសចរណ៍នៅក្នុងប្រទេសកម្ពុជា។ ជាមួយនឹងស្ពានតភ្ជាប់ដែនគោកទៅកោះ និងការអភិវឌ្ឍលើឆ្នេរហាវ៉ៃអាចពង្រីកតំបន់ច្រើនទៀតសំរាប់សកម្មភាពទេសចរណ៍ នឹងបង្កើនភ្ញៀវទេសចរណ៍មកកាន់ក្រុងព្រះសីហនុ ក៏ដូចជាខេត្តព្រះសីហនុ។



Draft

**ប្រាក់ចំណូលៈ** គំរោងនេះ នឹងបង្កើតប្រាក់ចំណូលសំរាប់ប្រជាជនមូលដ្ឋានដោយសារការផ្ដល់ការងារឱ្យធ្វើ នៅក្នុងដំណាក់កាលសាងសង់ និងប្រតិបត្តិគំរោង។ ប្រជាពលរដ្ឋមួយចំនួនអាចរកប្រាក់ពីកិច្ចការជំនួញរបស់ពួកគេផ្ទាល់។ ឧទាហរណ៍ ពួកគេអាចលក់ចំណីអាហារឱ្យកម្មករ និងបុគ្គលិកគំរោង។ ប្រជាជន អាចរកប្រាក់បានពីការលក់ផលិតផលរបស់ពួកគេនៅទីផ្សារក្នុងស្រុក និងផ្ដល់សេវាកម្មសំរាប់សកម្មភាពទេសចរណ៍។

**សេដ្ឋកិច្ចៈ** គំរោងមរកតមិនគ្រាន់តែបំរើទៅដល់វិស័យទេសចរណ៍ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបំរើទៅដល់វិស័យអភិវឌ្ឍន៍ផ្សេងៗទៀត ដូចជា ឧស្សាហកម្ម ពាណិជ្ជកម្ម ទូរគមនាគមន៍ និងវិស័យផ្សេងទៀត។ ហេតុដូចនេះហើយប្រាក់ចំណូល និងផលប្រយោជន៍ជាច្រើនបានមកពីវិស័យអភិវឌ្ឍន៍ខាងលើ នឹងបង្កើនជីវភាពរស់នៅរបស់ប្រជាជន និងកំនើនសេដ្ឋកិច្ចខេត្តព្រះសីហនុ ព្រមទាំងសេដ្ឋកិច្ចជាតិផងដែរ។

## ៦. ផែនការគ្រប់គ្រងបរិស្ថាន

### ៦.១ ការរៀបចំស្ថាប័ន

ការអនុវត្តន៍ ផ.គ.ប សំរាប់គំរោងនឹងត្រូវអនុវត្តដោយម្ចាស់គំរោង/ក្រុមហ៊ុនវិនិយោគ ក្នុងកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជំនាញ ដូចជា ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ គណៈកម្មការត្រួតពិនិត្យបទដ្ឋានបច្ចេកទេស មន្ទីរបរិស្ថានខេត្ត មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត នាយកដ្ឋានអង្កេតពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងនាយកដ្ឋានត្រួតពិនិត្យការបំពុល របស់ក្រសួងបរិស្ថាន រដ្ឋបាលជលផល រដ្ឋបាលព្រៃឈើ ខ័ណ្ឌរដ្ឋបាលជលផល ខ័ណ្ឌរដ្ឋបាលព្រៃឈើ អ្នកម៉ៅការ សាងសង់ និងអាជ្ញាធរមូលដ្ឋាន/ប៉ូលីស។

ម្ចាស់គំរោង/អ្នកវិនិយោគគំរោង ត្រូវទទួលខុសត្រូវរាល់ចំណាយទាំងអស់សំរាប់សំណងលើផលប៉ះពាល់ទាំងអស់ តំលៃសំរាប់វិធានការបន្ធូរបន្ថយបរិស្ថាន និងតំលៃត្រួតពិនិត្យតាមដានក្នុងរយៈពេលនៃការធ្វើវិនិយោគគំរោងទាំងមូល។ ធ្វើសហប្រតិបត្តិការ និងការសហការយ៉ាងល្អជាមួយអ្នកដែលពាក់ព័ន្ធគំរោង ដើម្បីធានាបាននូវរាល់ដំណាក់កាលនៃការអនុវត្តន៍គំរោងទាំងអស់ប្រព្រឹត្តិទៅយ៉ាងរលូន និងជោគជ័យ។

### ៦.២ វិធានការបន្ធូរបន្ថយបរិស្ថាន

គំរោងនឹងប៉ះពាល់ដល់ធនធានធម្មជាតិ និងសង្គមនៅក្នុង និងនៅជុំវិញតំបន់គំរោងដោយសារសកម្មភាពគំរោងមុនពេលសាងសង់ ពេលសាងសង់ និងពេលប្រតិបត្តិការ។ វិធានការបន្ធូរបន្ថយដែលបានស្នើឡើងដើម្បីកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមាននៃផ្នែកបរិស្ថាននិមួយៗ នៅក្នុងដំណាក់កាលផ្សេងគ្នារបស់គំរោង មានសង្ខេបនៅក្នុងតារាង ៧.២.១ នៃរបាយការណ៍ ។

Draft

## ៦.៣ កម្មវិធីត្រួតពិនិត្យតាមដានបរិស្ថាន

ការតាមដានលើចំណុចមួយចំនួនពីហេតុប៉ះពាល់បរិស្ថានបណ្តាលមកពីការសាងសង់ និងពេលប្រតិបត្តិជាតំរូវការចាំបាច់។ ស្ថាប័នទទួលខុសត្រូវ និងតំលៃសំរាប់អនុវត្តការពិនិត្យតាមដាន មានបញ្ចូលនៅក្នុងកម្មវិធីតាមដាន។ រាល់ការចំណាយទៅលើការត្រួតពិនិត្យតាមដានបរិស្ថានម្ចាស់គំរោងជាអ្នកទទួលខុសត្រូវ។

សង្ខេបតំលៃប៉ាន់ស្មានសំរាប់វិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន

| **បរិយាយ** | **តំលៃប្រចាំឆ្នាំ, USD** | **តំលៃសរុប, USD** |
|---|---|---|
| ***ដំណាក់កាលសាងសង់*** | | |
| ការត្រួតពិនិត្យគុណភាពទឹកនៅជុំវិញការដ្ឋានគំរោង។ ប៉ារ៉ាម៉ែត្រសំខាន់ៗសំរាប់ត្រួតពិនិត្យគុណភាពទឹក គឺ TSS, DO, BOD5, Total N, Total P, Cd, Hg, និង Pb។ បួនស្ថានីយ៍ នឹងត្រូវជ្រើសរើស។ | ២.០៤០.00 | ១០.២០០.00 |
| ***ដំណាក់កាលប្រតិបត្តិ*** | | |
| ការត្រួតពិនិត្យគុណភាពទឹកនៅជុំវិញការដ្ឋានគំរោង។ ប៉ារ៉ាម៉ែត្រសំខាន់ៗសំរាប់ត្រួតពិនិត្យគុណភាពទឹក គឺ TSS, DO, BOD5, Total N, Total P, Cd, Hg, និង Pb។ | ១.០២០.00 | ៩១.៨00.00 |
| ការធ្វើអង្កេតលើធនធានជលផល និងផ្កាថ្មជុំវិញកោះពស់ (ចំងាយ 0-១គ.មពីមាត់ទឹក) គ្រោងធ្វើជា រៀងរាល់២ឆ្នាំម្តង ពេញរយៈពេលប្រតិបត្តិគំរោងទាំងមូល។ | ១៥.000.00 | ៦៧៥.000.00 |
| **សរុប** | **១៨..០៦០.00** | **៧៧៧.000.00** |

Draft

សង្ខេបតំលៃប៉ាន់ស្មានសំរាប់កម្មវិធីត្រួតពិនិត្យបរិស្ថាន

| **បរិយាយ** | **តំលៃសរុប, USD** |
|---|---|
| **ដំណាក់កាលមុនសាងសង់** | ៨00.00 |
| **ដំណាក់កាលសាងសង់** | ១០.៦៥០.00 |
| **ដំណាក់កាលប្រតិបត្តិ** | ១១០.៣00.00 |
| **សរុប** | **១២១.៧៥០.00** |

# ៧. ការវាយតំលៃសេដ្ឋកិច្ច

នៅក្នុងជំពូកនេះត្រូវបានគេផ្តល់ឱ្យនូវទស្សនាទានពីការវិភាគសេដ្ឋកិច្ច ដោយប្រៀបធៀបគុណប្រយោជន៍ការអភិវឌ្ឍសេដ្ឋកិច្ចជាមួយនឹងផលប៉ះពាល់នៅក្នុងធនធានធម្មជាតិ និងសង្គមក្នុងតំបន់គំរោង ។

## ៧.១ តំលៃការអភិវឌ្ឍសរុប

ជាទូទៅ ការប៉ាន់ប្រមាណតំលៃអភិវឌ្ឍន៍សរុបសំរាប់គំរោងអភិវឌ្ឍន៍ រួមមានការសាងសង់រចនាសម្ព័ន្ធទ្រព្យសម្បត្តិលំនៅដ្ឋាន ការរៀបចំទីតាំងអភិវឌ្ឍន៍និមួយៗ តំលៃដី (ការជួលប្រចាំឆ្នាំ ឬកិច្ចសន្យាជួល) តំលៃការសាងសង់ស្ថាន ការបង់លើសេវាកម្មផ្សេងៗ តំលៃហេដ្ឋារចនាសម្ព័ន្ធខាងក្រៅ និងតំលៃផ្សេងៗទៀត។ តំលៃវិនិយោគសរុបគឺ **៤៤០លានដុល្លារអាមេរិក**។

## ៧.២ តំលៃធនធានធម្មជាតិ

**ហេតុប៉ះពាល់អវិជ្ជមានៈ**

ការកាប់ព្រៃឈើដែលមានផ្ទៃដីប្រហែល៤៦ហ.ត ឬក៏៤៧%នៃតំបន់ព្រៃឈើសរុបនៅលើកោះពស់សំរាប់ការសាងសង់ផ្លូវ អាគារ និងសំណង់រូបវ័ន្តផ្សេងៗទៀត នឹងប៉ះពាល់ដល់ធនធានព្រៃឈើនៅលើកោះពស់។ តំលៃលើការខូចខាតព្រៃឈើប្រមាណ១៨៥.៨០០ដុល្លាអាមេរិកសំរាប់តំលៃឈើមូល ហើយតំលៃ១.៨០០ដុល្លាអាមេរិកក្នុង១ឆ្នាំបន្ថែមទៀតសំរាប់ការកើនឡើងមាឌឈើ។ ប៉ុន្តែការប៉ាន់ប្រមាណ លើតំលៃឈើមូលប្រមាណ ១៨៥.៨០០ ដុល្លាអាមេរិកនេះ នឹងត្រូវបានដាក់បញ្ចូលទៅក្នុងគំរោងថវិកាជាតិ តាមរយៈការដាក់ឱ្យដេញថ្លៃជាសាធារណៈ ដោយរដ្ឋបាលព្រៃឈើនិងក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ។

ក្នុងដំណាក់កាលសាងសង់ និងប្រតិបត្តិគំរោងអាចនឹងប៉ះពាល់ដល់ការនេសាទត្រី។ គ្រួសារនេសាទប្រមាណជា២៥គ្រួសារ ដែលនឹងត្រូវបាត់បង់កន្លែងនេសាទត្រីនៅក្នុង និងជុំវិញតំបន់កោះពស់ ។

**ហេតុប៉ះពាល់វិជ្ជមាន :**

- សមិទ្ធផលនៃគំរោងនេះនឹងបន្ថែមហេដ្ឋារចនាសម្ព័ន្ធចំរុះនៅក្នុងក្រុងព្រះសីហនុ ដែលអាចផ្តល់បន្ថែមនូវមធ្យោបាយដល់វិស័យដឹកជញ្ជូន វិស័យពាណិជ្ជកម្ម និងវិស័យទេសចរណ៍នៅក្នុងតំបន់គំរោង ។
- តំបន់កោះពស់នឹងក្លាយទៅជាជំរកដ៏ល្អ សំរាប់ការបន្តពូជ និងការលូតលាស់នៃជំនាញក្រោយរបស់សត្វដែលរស់នៅក្នុង ទឹក/ត្រី។
- គំរោងនេះនឹងផ្តល់ការងារជាច្រើនដល់ប្រជាជនមូលដ្ឋានក្នុងខេត្តព្រះសីហនុ ចំនួន៩៥០នាក់ និង១៤៧០ នាក់ជាកម្មករ និងបុគ្គលិក ក្នុងដំណាក់កាលសាងសង់ និងប្រតិបត្តិគំរោង និងមានការងារជាច្រើនទៀតដែលកើតចេញពីវិស័យអភិវឌ្ឍន៍ដទៃទៀតដែលទាក់ទងទៅនឹងគំរោង។

Draft

- គំរោងនឹងបង្កើតប្រាក់ចំណូលដល់ប្រជាពលរដ្ឋក្នុងតំបន់គំរោង ដោយសារការផ្តល់ការងារឱ្យធ្វើក្នុងដំណាក់កាលសាងសង់ និងប្រតិបត្តិគំរោង និងវិស័យដទៃទៀត ដែលទាក់ទងទៅនឹងសកម្មភាពអភិវឌ្ឍគំរោង ។ ការប៉ាន់ប្រមាណលើប្រាក់ចំណូលរបស់ប្រជាពលរដ្ឋដោយសារគំរោង គឺប្រមាណ ២១០លានដុល្លាអាមេរិក ។
- ជាងនេះទៅទៀត តំលៃទុនវិនិយោគគំរោងសរុបប្រមាណ ៤៤០លានដុល្លាអាមេរិក (ថវិកាវិនិយោគបរទេស) និងពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំលើប្រតិបត្តិការគំរោង នឹងជាកត្តាមួយដើម្បីគាំទ្រដល់សេដ្ឋកិច្ចជាតិ ។

## ៧.៣ ការវិភាគហិរញ្ញវត្ថុ

ផ្អែកលើតំលៃលើការអភិវឌ្ឍសរុប (GDV) និងថ្លៃដើមលើការអភិវឌ្ឍសរុប (GDC) ដែលបានបញ្ជាក់ខាងលើ, លទ្ធផលនៃការវាយតំលៃហិរញ្ញវត្ថុបង្ហាញដូចខាងក្រោម:

| ទ្រនិចចង្អុលបង្ហាញ | លទ្ធផល |
|---|---|
| តំលៃការអភិវឌ្ឍសរុបក្រោយចុះបញ្ជីសារពើពន្ធ | ៥៩១.៤៩២.៣២៦ ដុល្លា |
| ថ្លៃដើមការអភិវឌ្ឍសរុប | ៤៤០.០៦៤.២០៩ ដុល្លា |
| លំហូរសាច់ប្រាក់សុទ្ធ (សមតុល្យចុងគ្រា) | ១៥១.៤២៨.១១៨ ដុល្លា |
| អត្រាផលទុនធនលាភធៀប (IRR) | ៤០,២៥ % |
| តំលៃបច្ចុប្បន្នសុទ្ធ (NPV) នៅ ១៨% | ៤៥.០២៤.៧២១ ដុល្លា |

ផ្អែកទៅតាមការវិភាគហិរញ្ញវត្ថុខាងលើគំរោងស្នើសុំអភិវឌ្ឍន៍ គឺត្រូវបានគេរំពឹងថានឹងបង្កើតអត្រាធនលាភភាព (IRR) ៤០,២៥% ។

នៅក្នុងព្រឹត្តិការណ៍ដែលទីផ្សារធ្លាក់ចុះ នោះតំលៃនៃសមាសភាពគំរោងស្នើសុំទាំងអស់ត្រូវបានថយចុះ៥% ហើយអត្រាធនលាភភាពនៃគំរោងត្រូវបានគេប៉ាន់ស្មានថា មានប្រហែល ៣៣,៩៦% ។ តែផ្ទុយមកវិញនៅក្នុងព្រឹត្តិការណ៍នៃទីផ្សារប្រសើរឡើង តំលៃនៃទ្រព្យសម្បត្តិទាំងនោះ នឹងត្រូវបានគេរំពឹងថាអាចកើនឡើង៥% ហើយជាលទ្ធផលនៅក្នុងការកើនឡើងតំលៃនៃអត្រាធនលាភភាពមានរហូតទៅដល់ ៤៦,១៥% ។

## ៧.៤ ការវិភាគសេដ្ឋកិច្ច នៃហេតុប៉ះពាល់បរិស្ថាន និងផលប្រយោជន៍

**ផលប្រយោជន៍សង្គម:** ហេដ្ឋារចនាសម្ព័ន្ធបរិវត្តបន្ថែមនៃផ្លូវគមនាគមន៍ដឹកជញ្ជូន ទេសចរណ៍ ពាណិជ្ជកម្ម និងវិស័យសុខភាព គឺបង្កភាពងាយស្រួលនៅក្នុងក្រុងព្រះសីហនុ ដែលជាតំបន់ប៉ូលអភិវឌ្ឍដ៏សំខាន់មួយបន្ទាប់ពីរាជធានីភ្នំពេញ និងក្រុងសៀមរាប ។

គំរោងបានផ្តល់បន្ថែមនូវឱកាសការងារដល់ប្រជាពលរដ្ឋកម្ពុជាពី ៩០០-១៤០០នាក់ ជាបុគ្គលិកគំរោង (៣-៥ឆ្នាំ) ក្នុងដំណាក់កាលសាងសង់ និង (៩០ឆ្នាំ) ក្នុងដំណាក់កាលប្រតិបត្តិ ។ បន្ថែមលើសនេះទៀត ប្រជាពល



Draft

រដ្ឋកម្ពុជារាប់ពាន់នាក់អាចធ្វើការនៅផ្នែកផ្សេងៗជាច្រើនទៀត ជាពិសេស ផ្នែកទេសចរណ៍ ការកើននូវភ្នាក់ងារទេសចរណ៍ សណ្ឋាគារ/ផ្ទះសំណាក់ ហាងទំនិញ ភោជនីយដ្ឋាន និងសេវាលើកម្មដឹកជញ្ជូន។ ការបង្កើតការងារ/មានការងារធ្វើចំពោះប្រជាពលរដ្ឋក្នុងស្រុកដោយសារសកម្មភាពគំរោងផ្ទាល់ និងវិស័យផ្សេងៗទៀត ទាក់ទងទៅនឹងការអភិវឌ្ឍគំរោង នឹងធ្វើឱ្យកំរិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងស្រុកបានប្រសើរឡើង និងអាចកាត់បន្ថយអត្រានៃភាពក្រីក្រនៅក្នុងខេត្តព្រះសីហនុ ក៏ដូចក្នុងប្រទេសទាំងមូលផងដែរ។

**ផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច:** គំរោងមរកតមិនគ្រាន់តែបំរើឱ្យផ្នែកទេសចរណ៍ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ការអភិវឌ្ឍលើវិស័យផ្សេងៗ ជាច្រើនទៀត ដូចជា វិស័យឧស្សាហកម្ម កសិកម្ម ពាណិជ្ជកម្ម ទូរគមនាគមន៍ និងវិស័យផ្សេងៗទៀត។ ហេតុនេះ ចំណូលនិងផលចំណេញជាច្រើនពីផ្នែកនៃការអភិវឌ្ឍខាងលើបានធ្វើឱ្យកំរិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកើនឡើង និង ការរីកចំរើននៃសេដ្ឋកិច្ចក្នុងខេត្តព្រះសីហនុ ព្រមទាំងសេដ្ឋកិច្ចជាតិ។

## ៨. សេចក្តីសន្និដ្ឋាន

ការសាងសង់គំរោងមរកតអាចមានហេតុប៉ះពាល់មធ្យមទៅលើធនធានធម្មជាតិដូចជា ព្រៃឈើ និងធនធានអេកូឡូស៊ីក្នុងតំបន់កោះពស់ ត្រី និងគុណភាពទឹកក្នុងដំណាក់កាលសាងសង់។ គំរោងអាចនឹងប៉ះពាល់តិចតួចទៅលើធនធានសង្គម ក្នុងនោះមាន បញ្ហាចរាចរណ៍ សកម្មភាពនេសាទត្រីរបស់អ្នកនេសាទនៅជុំវិញនិងក្បែរទីតាំងគំរោង សុខភាពសាធារណៈ ផ្លូវនាវាចរណ៍ (ក្នុងកន្លែងសាងសង់ស្ពាន) កាកសំណល់ និង សំលេងនិង រំញ័រ។ ទោះបីជាយ៉ាងណាក៏ដោយ វិធានការបន្ធូរបន្ថយត្រូវបានរៀបចំដាក់ក្នុងផែនការគ្រប់គ្រងបរិស្ថាន នឹងអាចកាត់បន្ថយហេតុប៉ះពាល់បានមួយចំនួនបន្ថែមទៀត។

យ៉ាងណាមិញ គំរោងបានផ្តល់ផលចំណេញជាច្រើនដល់ប្រជាពលរដ្ឋក្នុងតំបន់ ដូចជា ឱកាសការងារក្នុងដំណាក់កាលសាងសង់ និងប្រតិបត្តិការគំរោង។ គំរោងក៏បានបន្ថែមនូវហេដ្ឋារចនាសម្ព័ន្ធជាច្រើនក្នុងក្រុងព្រះសីហនុ ព្រមទាំងក្នុងខេត្តព្រះសីហនុផងដែរ ដែលផ្តល់បន្ថែមនូវមធ្យោបាយដល់វិស័យដឹកជញ្ជូន ពាណិជ្ជកម្ម និងទេសចរណ៍ក្នុងតំបន់គំរោង ដើម្បីសំរេចគោលដៅយុទ្ធសាស្ត្រការអភិវឌ្ឍសេដ្ឋកិច្ចនៃរាជរដ្ឋាភិបាលកម្ពុជា។ បន្ថែមពីលើនេះទៀត តំលៃទុនវិនិយោគគំរោងសរុបចំនួនប្រមាណ ៤៤០លានដុល្លាអាមេរិក (ទុនវិនិយោគបរទេស) និងពន្ធចំណូលប្រចាំឆ្នាំលើប្រតិបត្តិការគំរោងបានគាំទ្រដល់ការកើនឡើងនៃសេដ្ឋកិច្ចជាតិ។ ផ្អែកលើការវិភាគហិរញ្ញវត្ថុ គំរោងស្នើអភិវឌ្ឍលើកម្មវត្ថុអចលទ្រព្យគឺរំពឹងថានឹងបង្កើតអត្រាធនលាភភាព៤០%។ ហើយគំរោងត្រូវបានសង្ឃឹមថានឹងមានលទ្ធផលជាវិជ្ជមាន។

គំរោងអភិវឌ្ឍន៍មរកត បានផ្តល់លទ្ធភាពខ្ពស់លើផ្នែកហិរញ្ញវត្ថុ សេដ្ឋកិច្ច បរិស្ថានល្អ ដែលបានឆ្លើយតបផ្ទាល់ទៅនឹង "យុទ្ធសាស្ត្រចតុកោណ" របស់រាជរដ្ឋាភិបាលដែលនាំមកនូវការកើនឡើងនូវកំនើនសេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្រក្នុងសង្គមជាតិទាំងមូល។